# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារនៃការដាក់ឯកសារ

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០៤/២/០៧-០៩-២០០៩-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញាអន្តរជាតិ |
| ភាសាដើម | : | អង់គ្លេស |

## ចំណាត់ថ្នាក់ឯកសារ

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ:

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 23 / 03 / 2020
ម៉ោង (Time/Heure): 13:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

---

# ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសេចក្តីសង្ខេបអញ្ញត្រកម្មរបស់ អោ អាន តាមវិធាន ៨៩(១) នៃវិធានផ្ទៃក្នុង

---

**អ្នកដាក់ឯកសារ:**
សហព្រះរាជអាជ្ញាអន្តរជាតិ
លោក Brenda J. HOLLIS

**ចម្លងជូន៖**
សហព្រះរាជអាជ្ញាជាតិ
លោកស្រី ជា លាង

**អ្នកទទួលឯកសារ:**
អង្គជំនុំជម្រះសាលាដំបូង
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Claudia FENZ
ចៅក្រម យ៉ា សុខន
ចៅក្រម Martin KAROPKIN
ចៅក្រម យូរ ឧត្តរា

មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់
នៃសំណុំរឿង ០០៤/២

សហមេធាវី អោ អាន:
លោក មុំ លុជ្ជ
លោក Richard ROGERS
លោក Göran SLUITER

## I. សេចក្ដីផ្ដើម

1. សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") សូមឆ្លើយតបទៅនឹងសេចក្ដីសង្ខេបអញ្ញត្រកម្មរបស់ អោ អាន តាមវិធាន ៨៩(១) នៃវិធានផ្ទៃក្នុង ("អញ្ញត្រកម្ម")[1]។ ខណៈដែល ស.ព.អ បានកម្រិតចម្លើយតបរបស់ខ្លួនទៅនឹងបញ្ហានានាដែលបានលើកឡើងខាងក្នុងនោះ ដែល អោ អាន បានពង្រីកផ្អែកលើបញ្ហាទាំងអស់នេះនៅក្នុងបណ្ដឹងឧទ្ធរណ៍របស់គាត់[2]ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[3] ទៅអង្គបុរេជំនុំជម្រះ ("អ.ប.ជ") ស.ព.អ បានឆ្លើយតបយ៉ាងពេញលេញដូចដែលអាចធ្វើទៅបាននៅក្នុងចំនួនទំព័រដែលអាចរកបានទៅនឹងបញ្ហាលម្អិតនៃអំណះអំណាងដែលមានទាំងនេះ។ គាត់ស្នើសុំដោយគោរពថា គាត់នឹងទទួលបានឱកាសបន្ថែមទៀតដើម្បីឆ្លើយតប ក្នុងករណីដែលថា អង្គជំនុំជម្រះសាលាដំបូង ("អ.ជ.ស.ដ") ស្នើសុំឱ្យ អោ អាន បង្ហាញសារណាបន្ថែមទៀត។

2. ដូចបានរៀបរាប់លម្អិតខាងក្រោម ស.ព.អ ស្នើសុំឱ្យច្រានចោល អញ្ញត្រកម្មរបស់ អោ អាន[4]។

## II. ប្រវត្តិនីតិវិធី

3. នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ អង្គបុរេជំនុំជម្រះបានចេញ "សេចក្ដីពិចារណាបណ្ដឹងលើឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ" ដែលសម្រេចសេចក្ដីលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការសន្និដ្ឋានផ្អែកច្បាប់ខុសៗគ្នារបស់សហចៅក្រមស៊ើបអង្កេតទាំងពីររូប ("ស.ច.ស") ក្រោយពីបិទបញ្ចប់កិច្ចស៊ើបសួររបស់ខ្លួនទៅលើឧក្រិដ្ឋកម្មនានាដែលបានចោទប្រកាន់ប្រឆាំងនឹង អោ អាន[5]។ សេចក្ដីពិចារណាទាំងនេះត្រូវបានជូនដំណឹងទៅកាន់ក្រឡាបញ្ជី អ.ជ.ស.ដ និង ចៅក្រម អ.ជ.ស.ដ

---

[1] សេចក្ដីសង្ខេបអញ្ញត្រកម្មរបស់ អោ អាន តាមវិធាន ៨៩(១) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២០ ("អញ្ញត្រកម្ម")។#

[2] ឯកសារ **D360/5/1** បណ្ដឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងនឹងសេចក្ដីសម្រេចលើដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨ ("បណ្ដឹងឧទ្ធរណ៍របស់ អោ អាន")។#

[3] ឯកសារ **D360** ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ")។#

[4] ដូចដែលបានកត់សម្គាល់នៅខាងក្រោម ស.ព.អ មិនជំទាស់ទៅនឹងការដកបទចោទទី៣ (ឧក្រិដ្ឋកម្មថ្នាក់ជាតិ) ចេញពីដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះទេ។#

[5] ឯកសារ **D359/24 & D360/33** សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ("សេចក្ដីពិចារណា")។ ស.ច.ស.អ បានចោទប្រកាន់ និងឱ្យបញ្ជូនខ្លួន អោ អាន ទៅជំនុំជម្រះចំពោះអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភលើក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ចំណែកឯ ស.ច.ស.ជ បានលើកលែងចោទប្រកាន់ប្រឆាំងនឹងគាត់។#

ពីររូប[6]។ ក្នុងរយៈពេលបីខែបន្ទាប់ពីការចេញសេចក្តីពិចារណាទាំងអស់នេះរបស់ អ.ប.ជ រួចមក ទាំង ស.ព.អ[7] និង អោ អាន[8] បានដាក់ឯកសារជាច្រើនទៅកាន់ អ.ជ.ស.ដ។ ការដាក់ឯកសារនីមួយៗរបស់ ស.ព.អ ត្រូវបានដាក់ជាសំណៅរឹង ដោយបានចម្លងជូនចៅក្រម អ.ជ.ស.ដ និងភាគីនានាក្នុងសំណៅអេឡិចត្រូនិក[9]។ ទោះបីជាក្រឡាបញ្ជីរបស់ អ.ជ.ស.ដ បានទទួលស្គាល់ថាបានទទួលឯកសារទាំងអស់នេះ[10] មិនមានឯកសារណាមួយត្រូវបានជូនដំណឹងជាផ្លូវការឡើយ។

---

[6] *សូមមើល* សេចក្តីជូនដំណឹងតាមអ៊ីមែលពីមន្ត្រីកាន់សំណុំរឿង ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ម៉ោង ៤:៥៣ រសៀល។#

[7] (i) សំណើ [របស់ ស.ព.អ] សុំពន្យារកាលបរិច្ឆេទកំណត់តាមវិធាន ៨០ និងការរៀបចំកិច្ចប្រជុំសវនាការ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩។ (ii) ចម្លើយតប [របស់ ស.ព.អ] ទៅនឹងសំណើរបស់ អោ អាន ពាក់ព័ន្ធនឹងការទទួលសំណុំរឿង០០៤/២ ចុះថ្ងៃទី៦ ខែមករា ឆ្នាំ២០២០។ (iii) ការដាក់បញ្ជី [របស់ ស.ព.អ] ឈ្មោះសាក្សី និងអ្នកជំនាញតាមវិធាន ៨០ អមដោយឧបសម្ព័ន្ធសម្ងាត់ ក ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០។ (iv) សំណើ [របស់ ស.ព.អ] សុំឱ្យ [អ.ជ.ស.ដ] ចាត់វិធានការដើម្បីឱ្យបានចូលមើលដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសំណុំរឿង នៅក្នុងសំណុំរឿង០០៤/០២ (អោ អាន) ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២០។ (v) សំណើ [របស់ ស.ព.អ] សុំឱ្យបញ្ជាក់អំពីអ៊ីមែល [របស់ អ.ជ.ស.ដ]#ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ (អមដោយឧបសម្ព័ន្ធសាធារណៈពី ក-ច) ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០។#

[8] (i) អ៊ីមែលពី Göran Sluiter ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ នៅម៉ោង ៣:៣៣ រសៀល ដោយមាន ភ្ជាប់លិខិតមួយពីសហមេធាវីការពារក្តី ជូនទៅចៅក្រម អ.ជ.ស.ដ។ (ii) អ៊ីមែលពី Kristin Rosella នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០២០ នៅម៉ោង ៥:០៩ រសៀល ដោយមានភ្ជាប់អញ្ញត្រកម្ម។ (iii) អ៊ីមែលពី Kristin Rosella នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ នៅម៉ោង ៣:៤៨ រសៀល ភ្ជាប់ទៅនឹងបញ្ជីឈ្មោះសាក្សី និងអ្នកជំនាញតាមវិធាន ៨០ របស់ អោ អាន។#

[9] ការដាក់ឯកសារនីមួយៗត្រូវបានបញ្ជូនទៅឱ្យ អ.ជ.ស.ដ ជាសំណៅរឹង។ ចំណែកឯការចម្លងជូន *សូមមើល* (i)#អ៊ីមែល "សំណើសុំពន្យារពេលវេលា និងការរៀបចំកិច្ចប្រជុំសវនាការ ដាក់ទៅនឹងសំណុំរឿង០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/អ.ជ.ស.ដ" ផ្ញើដោយ ស.ព.អ នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៩ នៅម៉ោង ៣:៣៦ រសៀល។ (ii) អ៊ីមែល "ចម្លើយតបរបស់ ស.ព.អ ទៅនឹងលិខិតរបស់ អោ អាន ស្តីពីការទទួលយកសំណុំរឿងដោយអង្គជំនុំជម្រះ សាលាដំបូង" ផ្ញើដោយ ស.ព.អ នៅថ្ងៃទី៦ ខែមករា ឆ្នាំ២០២០ នៅម៉ោង ៣:៥៦ រសៀល។ (iii) អ៊ីមែល "ការចម្លយងជូននៃការដាក់ឯកសាររបស់ ស.ព.អ តាមវិធាន ៨០(១) នៃវិធានផ្ទៃក្នុង" ផ្ញើដោយ ស.ព.អ នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០ នៅម៉ោង ២:២៥ រសៀល។ (iv) អ៊ីមែល "ការចម្លងជូននៃសំណើរបស់ ស.ព.អ សុំឱ្យអង្គជំនុំជម្រះសាលាដំបូងចាត់វិធានការដើម្បីឱ្យបានចូលមើលដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសំណុំរឿង នៅក្នុង សំណុំរឿង០០៤/០២ (អោ អាន)" ផ្ញើដោយ ស.ព.អ នៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២០ នៅម៉ោង ៣:៣៩ រសៀល។ (v) អ៊ីមែល "ការចម្លងជូននៃសំណើរបស់ ស.ព.អ សុំឱ្យបញ្ជាក់អំពីអ៊ីមែលរបស់អង្គជំនុះជម្រះសាលាដំបូង# នៃថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ (ដោយមានឧបសម្ព័ន្ធសាធារណៈពី ក-ច)" ផ្ញើដោយ ស.ព.អ នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ នៅម៉ោង ៤:៣៤ រសៀល។#

[10] *សូមមើល* (i) អ៊ីមែល៖ "ព័ត៌មាន" ផ្ញើដោយក្រឡាបញ្ជី និងមន្ត្រីច្បាប់ លឹម ស៊ុយហុង ក្នុងនាម អ.ជ.ស.ដ នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ នៅម៉ោង ១:០០ រសៀល បានទទួលស្គាល់ការទទួលឯកសារដែលបានផ្ញើដោយភាគីនានា។ (ii) អ៊ីមែល៖

## III. ច្បាប់ជាធរមាន

4. តាមវិធាន ៨៩(១) នៃវិធានផ្ទៃក្នុង ភាគីអាចដាក់អញ្ញត្រកម្មទាក់ទងនឹង៖ ក) យុត្តាធិការរបស់អង្គជំនុំជម្រះ ខ) បញ្ហាណាមួយដែលត្រូវការសម្រាប់ការរំលត់កិច្ចដំណើរការនីតិវិធី និង/ឬ គ) មោឃភាពនីតិវិធីដែលត្រូវបានធ្វើបន្ទាប់ពីមានដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានដាក់។

5. វិធាន ៧៦(៧) នៃវិធានផ្ទៃក្នុងចែងថា "លើកលែងតែជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ ដីកាដំណោះស្រាយត្រូវកែតម្រូវកំហុសនៃការមិនគោរពវិធានបញ្ញត្តិក្នុងការស៊ើបសួរ។ គ្មានបញ្ហាណាមួយដែលពាក់ព័ន្ធនឹងកំហុសនីតិវិធីបែបនេះ អាចត្រូវបានលើកឡើងនៅ ចំពោះមុខ [អ.ជ.ស.ដ]"។

6. វិធាន ៧៧(១៣) ចែងថា៖ "សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ តម្រូវឱ្យមានសម្លេងគាំទ្រជាវិជ្ជមានពីចៅក្រម៤(បួន)រូបយ៉ាងតិច។ សេចក្តីសម្រេចនេះត្រូវបិទផ្លូវតវ៉ា។ ប្រសិនបើសម្លេងភាគច្រើនដែលតម្រូវមិនអាចរកបានទេ *សេចក្តីសម្រេចដែលមិនមានសម្លេងគាំទ្រ*របស់អង្គបុរេជំនុំជម្រះ*ត្រូវ*អនុវត្តដូចខាងក្រោម៖ [...] ខ-ក្នុងករណីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ [ស.ច.ស] ប្រសិនបើមិនអាចរកសម្លេងភាគច្រើនដែលតម្រូវបាននោះទេ អង្គបុរេជំនុំជម្រះត្រូវសម្រេច*ប្តឹងទៅ* [អ.ជ.ស.ដ] ដោយឈរលើមូលដ្ឋានដីកាដំណោះស្រាយរបស់ [ស.ច.ស][11]។"

7. វិធាន ៧៩(១) ចែងថា អ.ជ.ស.ដ ទទួលបណ្តឹងដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ ស.ច.ស ឬ អ.ប.ជ។

## IV. សារណា

### ក. អង្គជំនុំជម្រះសាលាដំបូងត្រូវបានប្តឹងឱ្យទទួលយកដោយត្រឹមត្រូវតាមច្បាប់នូវសំណុំរឿង០០៤/២ ដោយផ្អែកលើមូលដ្ឋាននៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងកិច្ចដំណើរការនីតិវិធីមិនអាចត្រូវបានរំលត់ទេ

8. អោ អាន ទទួលស្គាល់ថា អនុលោមតាមវិធាន ៧៧(១៣)(ខ) និង (ក) ទាំងដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងដីកាសម្រេចលើកលែងចោទប្រកាន់មានអានុភាព ដោយសារមិនមានសំឡេងភាគច្រើនលើសលុបរបស់ អ.ប.ជ ដើម្បីបដិសេធដីកាណាមួយនៅចុងបញ្ចប់នៃដំណើរការ

---

"ពាក់ព័ន្ធនឹងសំណើរបស់ ស.ព.អ ចុះថ្ងៃទី៤ ខែកម្ភៈ ឆ្នាំ២០២០" ផ្ញើដោយ លឹម ស៊ុយហុង ក្នុងនាម អ.ជ.ស.ដ នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ នៅម៉ោង ១១:៥៥ ព្រឹក។#

[11] គូសបញ្ជាក់បន្ថែម។#

បណ្តឹងឧទ្ធរណ៍[12]។ ទោះជាយ៉ាងណា គាត់យល់ខុសអំពីផលវិបាកនៃស្ថានភាពនេះ។ ផ្ទុយទៅនឹងការអះអាងរបស់ អោ អាន ដែលថា "ក្របខណ្ឌច្បាប់ អ.វ.ត.ក គ្មានសមត្ថភាពដោះស្រាយការជាប់គាំងនៃដីកាដំណោះស្រាយពីរខ្វែងគ្នានេះទេ"[13] វិធាន ៧៧(១៣)(ខ) *តម្រូវ* ថា អ.ជ.ស.ដ ត្រូវបានប្តឹងឲ្យទទួលយកដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅពេលដែលសំឡេងភាគច្រើនលើសលុបដែលត្រូវការរកមិនបានទេនោះ។ ជារួម អ.ជ.ស.ដ *ត្រូវបានប្តឹង* ដោយផ្អែកលើមូលដ្ឋាននៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ តាមវិធាន ៧៩(១) នៃវិធានផ្ទៃក្នុង។

9. ទោះបីជា ចៅក្រម អ.ប.ជ ខ្វែងយោបល់គ្នាលើនីត្យានុកូលភាពនៃដីកាដំណោះស្រាយនីមួយៗ ពួកគាត់បានឯកភាពគ្នាជាឯកច្ឆ័ន្ទថា នៅពេលដែលមិនមានសេចក្តីសម្រេចដោយសំឡេងភាគច្រើនលើសលុប គោលជំហរស្វ័យប្រវត្តិ - ដែលមានចែងនៅក្នុងកិច្ចព្រមព្រៀង អ.វ.ត.ក និងច្បាប់ អ.វ.ត.ក[14] - ដែលថា "ការស៊ើបអង្កេតត្រូវតែបន្តទៅមុខ"[15] គឺជា "មុខងារសំខាន់មាននៅក្នុងក្របខណ្ឌគតិយុត្ត អ.វ.ត.ក"[16] និងជា "មូលដ្ឋាន និងកត្តាកំណត់"[17]។ ចៅក្រម អ.ប.ជ បានសង្កត់ធ្ងន់ថា គោលជំហរស្វ័យប្រវត្តិនេះ "មិនអាចត្រូវបានទាត់ចោល ឬដកហូតឥទ្ធិពល និងទម្ងន់ពេញទាំងស្រុងរបស់វា ដោយការរៀបចំការបកស្រាយជាបណ្តាញ តាមរយៈការកេងចំណេញពីភាពមិនច្បាស់លាស់ ដែលអាចមាននៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុង ដើម្បីធ្វើឲ្យគោលការណ៍ស្នូលនេះក្លាយទៅជាគ្មានន័យនោះទេ"[18]។ ពួកគាត់បានពន្យល់ថា គោលបំណងរបស់វាគឺត្រូវ "ធានានូវយុត្តិធម៌ប្រកបដោយប្រសិទ្ធិភាព" និង "ជៀសវាងការជាប់គាំងផ្នែកនីតិវិធី ដែលអាចប៉ះពាល់ដល់ប្រសិទ្ធិភាពនៃកិច្ចដំណើរការនីតិវិធី"[19]។

10. ដូច្នេះ ការបកស្រាយតែមួយគត់នៃវិធាន ៧៧(១៣) និងវិធាន ៧៩(១) នៃវិធានផ្ទៃក្នុង ដែលអនុវត្តយ៉ាងត្រឹមត្រូវនូវច្បាប់ អ.វ.ត.ក និងកិច្ចព្រមព្រៀង អ.វ.ត.ក គឺការបកស្រាយ

---

[12] អញ្ញត្រកម្ម កថាខណ្ឌ ១៨-១៩។#

[13] អញ្ញត្រកម្ម កថាខណ្ឌ ២០។ *សូមមើលផងដែរ* កថាខណ្ឌ ១៧។#

[14] កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ៥(៤), ៧(៤)។ ច្បាប់ អ.វ.ត.ក មាត្រា ២៣ថ្មី។#

[15] ឯកសារ **D359/24 & D360/33** សេចក្តីពិចារណា កថាខណ្ឌ ១០៦-១០៧, ១១១-១១២, ១១៦-១១៧ (ជាឯកច្ឆ័ន្ទ)។#

[16] ឯកសារ **D359/24 & D360/33** សេចក្តីពិចារណា កថាខណ្ឌ ១០៦, ១១៤ (ជាឯកច្ឆ័ន្ទ)។#

[17] ឯកសារ **D359/24 & D360/33** សេចក្តីពិចារណា កថាខណ្ឌ ១១២ (ជាឯកច្ឆ័ន្ទ)។#

[18] ឯកសារ **D359/24 & D360/33** សេចក្តីពិចារណា កថាខណ្ឌ ១១២ (ជាឯកច្ឆ័ន្ទ)។#

[19] ឯកសារ **D359/24 & D360/33** សេចក្តីពិចារណា កថាខណ្ឌ ១១១ (ជាឯកច្ឆ័ន្ទ)។#

ដែលបញ្ជូនរឿងក្តី ០០៤/២ ទៅជំនុំជម្រះដោយផ្អែកលើមូលដ្ឋាននៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ដូច្នេះ វិធាន ៧៧(១៣)(ខ) គឺជា *វិធានពិសេស* (*lex specialis*) ធៀបទៅនឹង វិធាន ៧៧(១៣)(ក) ក្នុងករណីដែល អ.ប.ជ បរាជ័យមិនអាចរកសំឡេងភាគច្រើនលើសលុប ដើម្បីបដិសេធដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ យុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូល ("អ.ជ.ត.ក") គាំទ្រលទ្ធផលនេះ៖

> ឧទាហរណ៍ ប្រសិនបើ [អ.ប.ជ] សម្រេចថា [ស.ច.ស] ណាមួយមានកំហុសក្នុងការសម្រេចចេញ ឬក្នុងការស្នើឱ្យចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់ ដោយមូលហេតុថា ជនត្រូវចោទ គឺជា ឬមិនមែនជាជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ហើយប្រសិនបើ [អ.ប.ជ] មិនអាចទទួលបានសំឡេងគាំទ្រភាគច្រើនលើសលប់ ទៅលើផលវិបាកនៃសេណារីយ៉ូនេះទេ "ដំណើរការស៊ើបអង្កេតត្រូវបន្តទៅមុខ"[20]។

ទោះបីជា អ.ជ.ត.ក បានពិភាក្សាសេណារីយ៉ូនេះក្នុងបរិបទដែល ស.ច.ស បញ្ជូនដីកាដំណោះស្រាយផ្ទុយគ្នាដែលបានស្នើឡើងនេះទៅកាន់ អ.ប.ជ តាមយន្តការដោះស្រាយការខ្វែងយោបល់ផ្លូវការក៏ដោយ ក៏លទ្ធផលជាសារធាតុអាចអនុវត្តបានដូចគ្នានៅទីនេះ ក្នុងករណីដែល អ.ប.ជ មិនអាចរកសំឡេងភាគច្រើនលើសលុបបាន លើបញ្ហាថាតើ ស.ច.ស ណាម្នាក់មានកំហុសក្នុងការចេញដីកាសម្រេចលើកលែងចោទប្រកាន់ ឬដីកាបញ្ជូនរឿងទៅជំនុំជម្រះ[21]។ ការសម្រេចផ្សេងពីនេះនឹងមានលទ្ធផលដូចគ្នាបេះបិទទៅនឹងអ្វីដែលចៅក្រម អ.ប.ជ បានព្រមានជាឯកច្ឆ័ន្ទប្រឆាំងនឹង៖ ការដកហូតពីគោលជំហរស្វ័យប្រវត្តិក្នុងវិធាន ៧៧(១៣)(ខ) នូវទម្ងន់ និងឥទ្ធិពលដ៏ពេញលេញរបស់វា[22] ដែលនាំឱ្យមាន "លទ្ធផលផ្លូវច្បាប់ដែលមិនសមហេតុផលទាល់តែសោះ"[23]។

11. បទប្បញ្ញត្តិជាកាតព្វកិច្ចនៃវិធានទាំងនេះ ត្រូវបានគាំទ្របន្ថែមទៀតដោយគោលបំណងនៃកិច្ចព្រមព្រៀង របស់ អ.វ.ត.ក និង ច្បាប់ អ.វ.ត.ក ដែលត្រូវ "*កាត់សេចក្តី*មេដឹកនាំជាន់ខ្ពស់កម្ពុជា

---

[20] សំណុំរឿង០០១-ឯកសារ **F28** សាលដីកា *ឌុច* កថាខណ្ឌ ៦៥ *ដោយបានលើកឡើងពី* ច្បាប់ អ.វ.ត.ក មាត្រា ២៣ថ្មី។ កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ៧(៤)។ វិធាន ៧២(៤)(ឃ) នៃវិធានផ្ទៃក្នុង។ #

[21] *សូមមើលផងដែរ* ឯកសារ **D427/1/30** សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ២៧៤។

[22] *សូមមើល ខាងលើ* កថាខណ្ឌ ៩។#

[23] ឯកសារ **D359/24 & D360/33** សេចក្តីពិចារណា កថាខណ្ឌ ១១២ (ជាឯកច្ឆ័ន្ទ)។#

ប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម"[24] ក៏ដូចជាភ័ស្តុតាងអំពីចេតនាផ្ទាល់របស់ អ.ស.ប និង រាជរដ្ឋាភិបាលកម្ពុជា នៅពេលដែលពួកគេបិទបញ្ចប់កិច្ចព្រមព្រៀង អ.វ.ត.ក[25]។ ជាងនេះទៀត មានតែការបកស្រាយនេះទេដែលស្របទៅនឹងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិជាធរមាននៅ អ.វ.ត.ក ដែលតម្រូវឱ្យស្ថាប័ន អ.វ.ត.ក ធានាថាការស៊ើបអង្កេត និងការចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់ខ្លួនមានលក្ខណៈត្រឹមត្រូវ និងមានប្រសិទ្ធិភាព[26]។

12. ដូច្នេះ វិធាន ច្បាប់ អ.វ.ត.ក កិច្ចព្រមព្រៀង អ.វ.ត.ក និង យុត្តិសាស្ត្រ អ.ជ.ត.ក និង អ.ប.ជ *ទាំងអស់នេះ* កំណត់ថា រឿងក្តីនេះ*ត្រូវតែ*បញ្ជូនទៅជំនុំជម្រះ ផ្អែកលើមូលដ្ឋាននៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក្នុងពេលអវត្តមានសំឡេងភាគច្រើនលើសលុបរបស់ អ.ប.ជ ក្នុងការបដិសេធវា។

---

[24] កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ១ (គូសបញ្ជាក់បន្ថែម)។ ច្បាប់ អ.វ.ត.ក មាត្រា ១ (គូសបញ្ជាក់បន្ថែម)។#

[25] ឯកសារ **D324.30** លិខិតពីអគ្គលេខាធិការ អ.ស.ប ជូនចំពោះលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០០ ចំណារដែលបានភ្ជាប់ជាឧបសម្ព័ន្ធ ពីលោក Hans Corell ទៅកាន់លោកអគ្គលេខាធិការ ប្រធានបទ៖ សេចក្តីអំពាវនាវជាបន្ទាន់ពីប្រទេសកម្ពុជា - ជម្រើសដើម្បីដោះស្រាយការខ្វែងយោបល់គ្នារវាងចៅក្រមស៊ើបអង្កេត/ព្រះរាជអាជ្ញា ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០០ EN 01326090#(នៅថ្ងៃជាមួយគ្នាដែល អ.ស.ប បានផ្តល់ជាលើកដំបូងនូវមាត្រា ៧(៤) ដែលសរសេរទៅកាន់រាជរដ្ឋាភិបាលកម្ពុជា លោក Hans Corell អគ្គលេខាធិការរងទទួលបន្ទុកផ្នែកកិច្ចការច្បាប់ និងក្រុមប្រឹក្សាច្បាប់របស់ អ.ស.ប បានកត់ត្រានូវការសន្ទនាគ្នាមួយជាមួយនឹងលោកឧបនាយករដ្ឋមន្ត្រី សុខ អាន ប្រធានក្រុមចរចាររបស់រាជរដ្ឋាភិបាលកម្ពុជា ដោយការច្រានចោលនូវការអំពាវនាវរបស់គាត់ឲ្យមានលក្ខខណ្ឌតម្រូវមតិភាគច្រើនដាច់ខាត ដើម្បី*អនុម័តិឲ្យមាន*ការបន្តការស៊ើបសួរ ឬការចោទប្រកាន់។ លោក Hans Corell បានពន្យល់ថា យន្តការនៃការខ្វែងយោបល់គ្នាដូចដែលបានព្រាងនេះ មានន័យថា "អ្នកត្រូវការមតិភាគច្រើនលើសលុប ដើម្បីបញ្ឈប់ការស៊ើបសួរ ឬការចោទប្រកាន់")។ ឯកសារ **D324.36** សេចក្តីថ្លែងការណ៍ដោយលោក Hans Corell អគ្គលេខាធិការរង នៅពេលដែលចាកចេញពីភ្នំពេញនៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៣ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៣ EN 01326112។ *សូមមើលផងដែរ* ឯកសារ លោក David Scheffer# នៅក្នុង M. Cherif Bassiouni (ed) "អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ* បោះពុម្ពផ្សាយលើកទី៣ វ៉ុល្លូម III#ឆ្នាំ២០០៨ ទំព័រ២៤៦ (លោក David Scheffer#ដែលជាឯកអគ្គរដ្ឋទូតគោចររបស់ ស.រ.អា សម្រាប់បញ្ហាឧក្រិដ្ឋកម្មសង្គ្រាម និងបានចូលរួមយ៉ាងច្រើននៅក្នុងកិច្ចចរចារ បានបញ្ជាក់ទស្សនៈដូចគ្នាថា៖ "វិធីតែមួយគត់ដែលការចោទប្រកាន់ ឬការស៊ើបសួរត្រូវបាន*បញ្ឈប់* នោះគឺប្រសិនបើ [អ.ប.ជ] សម្រេចដោយសំឡេងភាគច្រើនលើសលុបថាវាគួរតែបញ្ឈប់។ សនិទានភាពនៅពីក្រោយនីតិវិធីនេះ គឺថា វារារាំងមិនឲ្យ [ស.ច.ស] ឬ សហព្រះរាជអាជ្ញាណាម្នាក់រាំងខ្ទប់ដល់ការស៊ើបសួរ ឬ ការចោទប្រកាន់ណាមួយ ដោយការខកខានមិនបានឈានដល់ការព្រមព្រៀងគ្នាមួយជាមួយនឹងដៃគូរបស់ខ្លួន ឬក៏ដោយគ្រាន់តែបង្អាក់ការស៊ើបសួរ ឬការចោទប្រកាន់បណ្តាលមកពីឥទ្ធិពលនយោបាយ ឬឥទ្ធិពលប្រភេទផ្សេងៗទៀត" (គូសបញ្ជាក់បន្ថែម))។#

[26] ឯកសារ **D359/24 & D360/33** សេចក្តីពិចារណា កថាខណ្ឌ ១១០-១១១ (ជាឯកជ្ជន្ទ)។#

ផ្លូវឆ្ពោះទៅមុខមានលក្ខណៈច្បាស់លាស់ និងមិនអាចបដិសេធបានដោយ ការលើកយករបស់ អោ អាន នូវគោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* នោះទេ ដោយហេតុថាមិនមាន "ការសង្ស័យ" ត្រូវដោះស្រាយឡើយ[27]។ ជាងនេះទៀត *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* មិនអាចអនុវត្តបានចំពោះបញ្ហានីតិវិធី ដូចជាបញ្ហានេះទេ ដែលសំណួរនោះគឺថា តើអត្ថបទពាក់ព័ន្ធគួរត្រូវបានបកស្រាយដើម្បីបញ្ជូនជនជាប់ចោទទៅជំនុំជម្រះ ឬយ៉ាងណា។ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* គឺជាផលវិបាកនៃសច្ចធារណ៍នៃនិរទោស និងជាផ្នែកមួយនៃលក្ខខណ្ឌតម្រូវដែលថា ពិរុទ្ធភាពត្រូវតែរកឱ្យឃើញ *នៅពេលជំនុំជម្រះ* ឱ្យហួសពីវិមតិសង្ស័យ[28]។ វាបង្ហាញឱ្យឃើញនូវការរកឃើញជាស្វ័យប្រវត្តិ ក្នុងករណីដែលថា ការសង្ស័យផ្នែកអង្គហេតុមិនត្រូវបានលុបបំបាត់ដោយភ័ស្តុតាង[29]។ និយាយម្យ៉ាងវិញទៀត ជាពិសេសវាជាវិធាននៃការបង្ហាញភ័ស្តុតាង និងមិនមែនជាវិធានស្តីពីការបកស្រាយច្បាប់នោះទេ។ ក្នុងករណីដ៏កម្រដែលវាអនុវត្តទៅលើបញ្ហាច្បាប់ គោលការណ៍នេះដោះស្រាយជាចំបងអំពីការសង្ស័យទាក់ទងនឹងច្បាប់ព្រហ្មទណ្ឌ*សារធាតុ* ពីព្រោះវាជាច្បាប់ព្រហ្មទណ្ឌសារធាតុ ដែលសម្រេចពិរុទ្ធភាពរបស់ជនជាប់ចោទ មិនមែនច្បាប់ស្តីពីនីតិវិធីទេ[30]។

13. ក្នុងករណីណាក៏ដោយ លទ្ធភាពអនុវត្តបានដ៏តិចតួចចំពោះភាពមិនច្បាស់លាស់ផ្នែកច្បាប់ គឺត្រូវបានកម្រិតត្រឹមការសង្ស័យដែលនៅសេសសល់ បន្ទាប់ពី*ការបកស្រាយ*ប្រើវិធានច្បាប់ស៊ីវិល គឺថា ក្រោយពីពិចារណាលើភាសានៃបទប្បញ្ញត្តិនោះ ទីតាំងរបស់វានៅក្នុងប្រព័ន្ធ (រួមបញ្ចូលទាំងទំនាក់ទំនងរបស់វាទៅនឹងគោលការណ៍ជាមូលដ្ឋានដ៏សំខាន់) និងគោលបំណងរបស់វា[31]។ អង្គហេតុ

[27] អញ្ញត្រកម្ម កថាខណ្ឌ ១៧, ២០-២១។#

[28] រាល់ជនជាប់ចោទទាំងអស់ រួមទាំង អោ អាន ផង ទទួលបាននូវសច្ចធារណ៍នៃនិរទោស លើកលែង និងរហូតទាល់តែពួកគាត់ត្រូវបានកាត់ឱ្យជាប់ទោសដោយមតិភាគច្រើនលើសលុបនៃចៅក្រម អ.ជ.ស.ដ៖ វិធាន ៩៨(៤) នៃវិធានផ្ទៃក្នុង។ ឯកសារ **D359/24** & **D360/33** សេចក្តីពិចារណា កថាខណ្ឌ ១៦៣ (ជាឯកច្ឆ័ន្ទ)។#

[29] *សូមមើល ឧទា.* សំណុំរឿង០០២-ឯកសារ **E50/3/1/4** សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើសំណើសុំដោះលែងរបស់ ខៀវ សំផន កថាខណ្ឌ ៣១។ សំណុំរឿង០០៣- ឯកសារ **D87/2/1.7/1/1/7** សេចក្តីសម្រេច អ.ប.ជ ស្តីពីចំណងទាក់ទង កថាខណ្ឌ ៦៥។ សាលក្រម *Stakić* កថាខណ្ឌ ៤១៦។ #

[30] *សូមមើល ឧទា.* លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា ២២(២)។ សាលដីកាលើបណ្តឹងសាទុក្ខស្តីពីសក្ខីកម្មដែលបានកត់ត្រាពីមុនរបស់ *Gbagbo & Goudé* កថាខណ្ឌ ៨៣។#

[31] សំណុំរឿង០០២-ឯកសារ **E50/3/1/4** សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើសំណើសុំដោះលែងរបស់ ខៀវ សំផន កថាខណ្ឌ ៣១។ សាលក្រម *Čelebići* កថាខណ្ឌ ៤១៣។ សំណុំរឿង០០៤/១-ឯកសារ **D308/3** ដីកាដំណោះស្រាយ កថាខណ្ឌ ២៦។#

ដែលថា សេណារីយ៉ូជាក់លាក់មួយមិនត្រូវបានគ្រប់ដណ្ដប់ដោយផ្ទាល់ដោយអត្ថបទច្បាប់ មិនធ្វើឱ្យវា "គ្មានការចែងកំណត់"[32] ឬបង្កើតឱ្យមាន "ការសង្ស័យ" ដែលចុងចោទតែងតែទទួលបានផលប្រយោជន៍ទេ។ ដូចដែល អ.ជ.ត.ក បានសម្រេចថា "ដូចនេះ [...] គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* នឹងមិនមានភាពចាំបាច់ ក្នុងការដោះស្រាយទៅលើ*ភាពខ្វះចន្លោះ*នៃច្បាប់ឡើយ"[33]។

14. ទោះបីជាវាគឺជាគោលជំហររបស់ ស.ព.អ ដែលថា មិនមាន*ភាពខ្វះចន្លោះ*នៃច្បាប់កើតមាននៅទីនេះក្ដី នៅពេលដែលបញ្ហានីតិវិធីមិនត្រូវបានដោះស្រាយដោយវិធាននេះ វិធាន២ នៃវិធានផ្ទៃក្នុងណែនាំស្ថាប័នធ្វើការសម្រេចចិត្តរបស់ អ.វ.ត.ក ឱ្យសម្រេចលើបញ្ហានេះស្របទៅនឹងច្បាប់កម្ពុជា និងវិធានស្ដីពីនីតិវិធីដែលពាក់ព័ន្ធ និងដោយគោរពសិទ្ធិរបស់ភាគី *ទាំងអស់*។ វិធានពាក់ព័ន្ធទាំងអស់នេះរួមមាន មាត្រា២៣ថ្មី នៃច្បាប់ អ.វ.ត.ក ដែលចែងថា "ការស៊ើបអង្កេតត្រូវតែបន្តទៅមុខ"។ កត់សម្គាល់ថា វិធាន ២ នៃវិធានផ្ទៃក្នុងមិនបានអនុញ្ញាតឱ្យមានការសន្និដ្ឋានជាក់ស្ដែងជាស្វ័យប្រវត្តិក្នុងប្រយោជន៍របស់ជនជាប់ចោទនោះទេ។ ផ្ទុយទៅវិញ វិធាននេះតម្រូវថា ត្រូវផ្ដោតការយកចិត្តទុកដាក់លើវិធាន២១ នៃវិធានផ្ទៃក្នុង ដែល អ.ជ.ត.ក បានបញ្ជាក់ថា "មិន [...] ផ្ដល់ផលប្រយោជន៍ឱ្យជនជាប់ចោទដោយស្វ័យប្រវត្តិនៅក្នុងគ្រប់ស្ថានភាពជាក់លាក់ដែលកើតចេញពីការបកស្រាយនៃវិធានផ្ទៃក្នុងឡើយ"។ ការពិចារណាពាក់ព័ន្ធគឺថា ការបកស្រាយនេះមិនប៉ះពាល់ដល់សិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទទេ[34]។ អានខ្លឹមសារទាំងស្រុងរបស់វា វិធាននេះតម្រូវថា ច្បាប់ អ.វ.ត.ក និងវិធានផ្ទៃក្នុងត្រូវបកស្រាយដើម្បីការពារមិនត្រឹមតែផលប្រយោជន៍របស់ជនជាប់ចោទនោះទេ ប៉ុន្តែថែមទាំងជនរងគ្រោះផងដែរ និងថា កិច្ចដំណើរការនីតិវិធី អ.វ.ត.ក ត្រូវតែ "ថែរក្សាតុល្យភាពរវាងសិទ្ធិរបស់ភាគី"។ វាគឺជាគោលការណ៍ជាមូលដ្ឋាននៃច្បាប់ អ.វ.ត.ក[35] និងតុលាការអន្តរជាតិ[36] ព្រមទាំងជាដំណើរការច្បាប់របស់ប្រទេសបារាំង

---

[32] *ផ្ទុយទៅនឹង* អញ្ញត្រកម្ម កថាខណ្ឌ ១៧។#

[33] សំណុំរឿង០០២-**E50/3/1/4** សេចក្ដីសម្រេចរបស់ អ.ជ.ត.ក លើសំណើសុំដោះលែងរបស់ ខៀវ សំផន កថាខណ្ឌ ៣១។ #

[34] *សូមមើល ឧទា.* សំណុំរឿង០០២-ឯកសារ **E50/2/1/4** សេចក្ដីសម្រេចរបស់ អ.ជ.ត.ក លើសំណើសុំដោះលែងរបស់ នួន ជា និង អៀង ធីរិទ្ធ កថាខណ្ឌ ៣៩។ សំណុំរឿង០០២-ឯកសារ **E50/3/1/4** សេចក្ដីសម្រេចរបស់ អ.ជ.ត.ក លើសំណើសុំដោះលែងរ បស់ ខៀវ សំផន កថាខណ្ឌ ៣០។ សំណុំរឿង០០២-ឯកសារ **E154/1/1/4** សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខស្ដីពីការប្រាស្រ័យទាក់ទងការងារជាមួយតែភាគីម្ខាង កថាខណ្ឌ ១៤។#

[35] វិធាន ២១(១) នៃវិធានផ្ទៃក្នុង។ *សូមមើលបន្ថែមទៀត* មហាសន្និបាតអង្គការសហប្រជាជាតិ សេចក្ដីប្រកាសពីគោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះនៃឧក្រិដ្ឋកម្ម និងការរំលោភអំណាច G៱1Res 40/34 នៃថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ

និងកម្ពុជា[37] ដែល បើអនុលោមតាមគោលការណ៍នៃភាពស្មើគ្នា សិទ្ធិទទួលបានការជំនុំជម្រះក្តីមួយដែលត្រឹមត្រូវយុត្តិធម៌ មិនមែនជាកម្មសិទ្ធិរបស់ក្រុមការពារក្តីតែម្នាក់ឯងនោះទេ វាគឺជាសិទ្ធិរបស់ភាគីទាំងអស់នៃកិច្ចដំណើរការនីតិវិធី រួមទាំងជនរងគ្រោះផង និងអយ្យការដែលបំពេញកិច្ចក្នុងនាម និងក្នុងផលប្រយោជន៍សង្គមកម្ពុជា និងមនុស្សជាតិទាំងអស់។ ការធ្វើតាមតែជនជាប់ចោទចំពោះបញ្ហាខាងនីតិវិធី នឹងធ្វើឱ្យមានផលប៉ះពាល់ដ៏គួរឱ្យខ្លាចទៅលើរដ្ឋបាលរបស់អង្គជំនុំជម្រះជាមិនខាន[38]។

15. ផ្ទុយទៅនឹងគោលជំហររបស់ អោ អាន បើសិនជាភាពមិនប្រាកដប្រជាខាងនីតិវិធីទាំងអស់នឹងត្រូវបានអនុញ្ញាតជាផលប្រយោជន៍ដល់ជនត្រូវចោទដោយស្វ័យប្រវត្តិ រហូតដល់ចំណុចដែល

---

១៩៨៥ គោលការណ៍ទី៤ (“ជនរងគ្រោះត្រូវតែទទួលបានការប្រព្រឹត្តដោយសេចក្តីអាណិតអាសូរ និងការគោរពចំពោះសេចក្តីថ្លៃថ្នូររបស់ពួកគាត់។ ពួកគាត់ត្រូវមានសិទ្ធិចូលរួមក្នុងយន្តការយុត្តិធម៌ និងទទួលបានដំណោះស្រាយភ្លាមៗ ដូចដែល ត្រូវបានចែងដោយច្បាប់ជាតិ ចំពោះព្យសនកម្មដែលពួកគាត់បានទទួលរង”)។#

[36] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីការទទួលយកភ័ស្តុតាងរបស់ *Aleksovski* កថាខណ្ឌ ២៥។ *សូមមើលផងដែរ* សេចក្តីសម្រេចលើការចោទប្រកាន់ពីការបើកឡើងវិញនូវសំណុំរឿងរបស់ *Zigiranyirazo* កថាខណ្ឌ ១៨។ *Karemera* សេចក្តីសម្រេចលើការបំបែកដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ២៦។#

[37] <u>បារាំង:</u> ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង (“FCCP”), Article préliminaire (“La procédure pénale doit être équitable et contradictoire et préserver l’équilibre des droits des parties. […] L’authorité judiciaire veille […] à la garantie des droits des victimes au cours de toute procédure pénale.” បកប្រែក្រៅផ្លូវការ៖ កិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌត្រូវតែស្មើភាព និងអាចដេញដោលគ្នាបាន ហើយនឹងថែរក្សាតុល្យភាពរវាងសិទ្ធិរបស់ភាគី។ […] អាជ្ញាធរតុលាការត្រូវធានាចំពោះសិទ្ធិរបស់ជនរងគ្រោះនូវទូទាំងកិច្ចដំណើរការនីតិវិធីទាំងមូល”)។ Conseil Constitutionnel, No. 95-360, ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ១៩៩៥ កថាខណ្ឌ ៥ (“Considérant […] que le principe du respect des droits de la défense constitue un des principes fondamentaux reconnus par les lois de la République […]; qu’il implique, notamment en matière pénale, l’existence d’une procédure juste et équitable garantissant l’équilibre des droits des parties”. បកប្រែក្រៅផ្លូវការ៖ “ដោយពិចារណា […] ថា គោលការណ៍គោរពសិទ្ធិរបស់មេធាវីការពារក្តី គឺជាគោលការណ៍ជាមូលដ្ឋានមួយដែលបានទទួលស្គាល់ដោយច្បាប់ [របស់ប្រទេសបារាំង]; ដែលវាបង្កប់ន័យ ក្នុងរឿងព្រហ្មទណ្ឌ អំពីអត្ថិភាពនៃនីតិវិធីដែលមានភាពយុត្តិធម៌ និងស្មើភាពគ្នា ដែលមានការធានាចំពោះតុល្យភាពរវាងសិទ្ធិរបស់ភាគី”)។ *សូមមើលផងដែរ* Pradel, J.„ *Manuel de Procédure Pénale* (បោះពុម្ពផ្សាយលើកទី ១៤), ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៨ ទំព័រទី ១៤១ [“le parquet est une partie originale à ce procès, une partie différente des autres, car il défend les intérêts de la société.” បកប្រែក្រៅផ្លូវការ៖ “រដ្ឋអាជ្ញាគឺជាភាគីដើមនៃដំណើរការនេះ ជាភាគីមួយខុសពីភាគីផ្សេងទៀត ដោយសារគាត់ការពារផលប្រយោជន៍សង្គម”]។ <u>កម្ពុជា:</u> ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ៤ (“បណ្តឹងអាជ្ញាត្រូវអនុវត្តក្នុងនាមនៃផលប្រយោជន៍ទូទៅដោយអយ្យការ”)។#

[38] *Boddaert ទល់នឹង ប្រទេសបែលហ្សិក* កថាខណ្ឌ ៣៩។ *Neumeister ទល់នឹង ប្រទេសអូទ្រីស* កថាខណ្ឌ ២១។ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ២។#

អាចរលត់កិច្ចដំណើរការនីតិវិធីបានមែន នោះវាជាការរំលោភច្បាប់នីតិវិធីកម្ពុជា (និង ច្បាប់នីតិវិធីបារាំង)។ តាមនីតិវិធីកម្ពុជា មូលហេតុនៃការរលត់បណ្តឹងអាជ្ញា គឺមានចែងយ៉ាងច្បាស់នៅក្នុងមាត្រា ៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមានការកម្រិតចំពោះមរណភាពនៃជនជាប់ចោទ ការផុតអាជ្ញាយុកាល ការលើកលែងទោស និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌនិង*អាជ្ញាអស់ជំនុំ*[39]។ អ.ជ.ត.ក និង អ.ជ.ស.ដ ទាំងពីរនេះសុទ្ធតែបានសម្រេចថា ហេតុដូច្នេះ អ.វ.ត.ក គ្មានសិទ្ធិអំណាចបង្គាប់ឱ្យរលត់ កិច្ចដំណើរការនីតិវិធីដោយសារមូលហេតុដទៃផ្សេងទៀតឡើយ[40]។ យុត្តិសាស្ត្រនៅថ្នាក់អន្តរជាតិ[41] ក៏បង្កើតចំណុចចាប់ផ្តើមអប្បរមាខ្ពស់បំផុតសម្រាប់ការរំលត់ ឬផ្អាកកិច្ចដំណើរការនីតិវិធីផងដែរ[42]។

16. ជាចុងក្រោយ កិច្ចព្រមព្រៀង អ.វ.ត.ក ចែងថា៖ "[សេចក្តីសម្រេចចិត្តរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ ៥៧/២២៨] មហាសន្និបាតបានទទួលស្គាល់ការព្រួយបារម្ភពេញច្បាប់របស់រដ្ឋាភិបាល និងប្រជាជនកម្ពុជាក្នុង*ការស្វែងរកយុត្តិធម៌ និងការបង្រួបបង្រួមជាតិ* ស្ថេរភាព សន្តិភាព និងសន្តិសុខ"[43]។ ការណ៍នេះតម្រូវឱ្យចៅក្រម និងអង្គជំនុំជម្រះ អ.វ.ត.ក ទាំងពីរ ស្វែងរកការពិតអំពីអ្វីដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា[44] និងធានាដល់ការចូលរួម

---

[39] <u>កម្ពុជា:</u> ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ៧។ *សូមមើលបន្ថែមទៀត* ទាក់ទងនឹងច្បាប់នីតិវិធី<u>បារាំង</u> មាត្រា៦។#

[40] សំណុំរឿង០០២-ឯកសារ **E138/1/10/1/5/7** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីការដោះលែង អៀង ធីរិទ្ធ កថាខណ្ឌ ៣៨។ សំណុំរឿង០០២-ឯកសារ **E116** សេចក្តីសម្រេចលើសំណើរបស់ នួន ជា ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ កថាខណ្ឌ ១៦-១៧។ សំណុំរឿង០០២-ឯកសារ **E189/3** សេចក្តីសម្រេចលើសំណើសុំឱ្យមានចំណាត់ការជាបន្ទាន់ កថាខណ្ឌ ៩។#

[41] ច្បាប់ អ.វ.ត.ក មាត្រា ៣៣ថ្មី។#

[42] ការរលត់ ឬផ្អាកកិច្ចដំណើរការនីតិវិធី ត្រូវបានអនុវត្តដោយតុលាការអន្តរជាតិដទៃទៀតម្តងម្កាលដែរ ប៉ុន្តែមានតែឧទាហរណ៍តិចតួចប៉ុណ្ណោះ និងឆ្លុះបញ្ចាំងអំពីស្ថានភាពផ្សេងៗដែលគេបានពិចារណាថា ភាពមិនអាចបន្តទៅមុខ គឺជាឧបាស្រ័យ*តែមួយគត់* ដែលអាចធានាដល់ភាពត្រឹមត្រូវយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី ឬបើមិនដូច្នោះទេ គឺវាមានភាពចាំបាច់សម្រាប់ផលប្រយោជន៍យុត្តិធម៌។ *សូមមើល ឧទា.* សេចក្តីសម្រេចលើញត្តិស្នើសុំផ្អាកកិច្ចដំណើរការនីតិវិធីរបស់ *Karadžić* #កថាខណ្ឌ៤ (ទទួលស្គាល់ថាឧបាស្រ័យហួសហេតុនៃការផ្អាកកិច្ចដំណើរការនីតិវិធីអាចនឹងធ្វើបាន កាលណាការរំលោភសិទ្ធិមនុស្សរបស់ជនជាប់ចោទ មានលក្ខណៈធ្ងន់ធ្ងររហូតដល់ការជំនុំជម្រះដោយត្រឹមត្រូវមិនអាចធ្វើបាន)។ សាលដីកាលើយុត្តាធិការរបស់ *Lubanga* កថាខណ្ឌ ៣០។#

[43] កិច្ចព្រមព្រៀង អ.វ.ត.ក បុព្វកថា (គូសបញ្ជាក់បន្ថែម)។#

[44] *សូមមើល ឧ.* វិធាន៥៥(៥) វិធាន៨៧(៤) នៃវិធានផ្ទៃក្នុង។ សំណុំរឿង០០២-ឯកសារ **D164/3/6** សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភ័ស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុករួម កថាខណ្ឌ៣៥។ សំណុំរឿង ០០៣-ឯកសារ **D120/3/1/8** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ស្តីពីញត្តិសុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ បន្ថែម

ប្រកបដោយអត្ថន័យរបស់ជនរងគ្រោះនៃឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តឡើងជាផ្នែកនៃការស្វែងរកការបង្រួបបង្រួមជាតិ[45]។ ពីមុន អ.ប.ជ ធ្លាប់បានកំណត់ថា "ការបញ្ចូលភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងកិច្ចដំណើរការនីតិវិធី គឺជាការទទួលស្គាល់ការស្វែងរកការបង្រួបបង្រួមជាតិដូចបានពោលខាងលើ"[46]។ ប៉ុន្តែ ការទាត់ចោលសំណុំរឿង ០០៤/២ នៅដំណាក់កាលនេះ គឺជាការរំលោភសិទ្ធិជាក់លាក់ ដែលបានផ្តល់ឱ្យដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងក្របខណ្ឌរបស់ អ.វ.ត.ក រួមទាំងសិទ្ធិចូលរួមក្នុងកិច្ចដំណើរការនីតិវិធីតុលាការ សិទ្ធិធ្វើសវនាការអំពីរឿងរ៉ាវរបស់ខ្លួន និងសិទ្ធិស្វែងរកសំណង[47]។ វាក៏នឹងបង្កើតបានជាការប្រមាថមួយចំពោះមនុស្សប្រុស ស្រីគ្រប់រូបដែលបានចូលខ្លួនមកបង្ហាញភ័ស្តុតាងដល់ ស.ច.ស ព្រមទាំងមានតម្លៃស្មើនឹងការបរាជ័យនៅក្នុងការផ្តល់នូវវិធានការយុត្តិធម៌ណាមួយដល់ជនរងគ្រោះរាប់ម៉ឺននាក់ ដែលពួកគេកំពុងតែទន្ទឹងរង់ចាំការទទួលខុសត្រូវអស់រយៈពេលជាងបួនទសវត្សរ៍មកនេះ។

## ខ. ថាតើ អោ អាន គឺជាមេដឹកនាំជាន់ខ្ពស់ និង/ឬជនដែលទទួលខុសត្រូវខ្ពស់បំផុត ឬយ៉ាងណានោះ មិនមែនជាប្រធានបទនៃការជំនុំជម្រះនៅចំពោះមុខ អ.ជ.ស.ដ ទេ

កថាខណ្ឌ ៣៦ (លើទំព័រ ៣៧) (ចៅក្រម Beauvallet និង Baik)។ Cass. Crim., ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ១៩៦៦ លេខ 66-90.134 ("alors que la juridiction de renvoi est sur le point d'être saisie et que l'interêt de la manifestation de la verité continue, jusqu'au jugement à intervenir"។ ការបកប្រែក្រៅផ្លូវការ៖ ខណៈតុលាការជំនុំជម្រះហៀបនឹងទទួល ហើយចំណាប់អារម្មណ៍ក្នុងបង្ហាញឱ្យឃើញនូវការពិត បន្តរហូតដល់ពេលដែលសាលក្រម [សាលាដំបូង] បានចេញ")។ Cass. Crim ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ១៩៧៩ លេខ 78-92.277 ("Attendu […] qu'il appartient aux juges correctionnels d'ordonner les mesures d'information qu'ils constatent avoir été omises et qu'ils déclarent utiles à la manifestation de la vérité". ការបកប្រែក្រៅផ្លូវការ៖ ដោយហេតុថា វាជារឿងចាំបាច់ដែលចៅក្រមជំនុំជម្រះបង្គាប់ឱ្យ មានវិធានការស៊ើបអង្កេតដែលពួកគាត់ដឹងថាមិនបានធ្វើ និងកំណត់ថាមានប្រយោជន៍សម្រាប់ការបញ្ជាក់ការពិត")។ *សូមមើលបន្ថែម Karadžić & Mladić* #សេចក្តីសម្រេចលើការពិនិត្យមើលដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៣ ("យុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ […] ត្រូវបំពេញបេសកកម្មរបស់ខ្លួនក្នុងការលាតត្រដាងការពិតអំពីអំពើដែលបានប្រព្រឹត្ត និងការឈឺចាប់ដែលបានកើតចេញអំពីវា ព្រមទាំងធ្វើការកំណត់អត្តសញ្ញាណ និងចាប់ខ្លួនជនជាប់ចោទទាំងឡាយដែលមានការទទួលខុសត្រូវ")។#

[45] សំណុំរឿង ០០២-ឯកសារ **D411/3/6** សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៦៤-៦៥។#

[46] សំណុំរឿង ០០២-ឯកសារ **C11/53** សាលដីកាអំពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌ ៣៧។#

[47] វិធាន ២៣(១), វិធាន ៨០(២) នៃវិធានផ្ទៃក្នុង។#

17. ស.ច.ស បានសម្រេចថា អោ អាន គឺជាមន្ត្រីខ្មែរក្រហម "ទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃសម័យកាលកម្ពុជាប្រជាធិបតេយ្យ[48]។ ការអះអាងរបស់ អោ អាន ថា ពេលនេះ អ.ជ.ស.ដ មិនមានយុត្តាធិការបុគ្គលលើគាត់ ពីព្រោះគាត់មិនមែនជា "មេដឹកនាំជាន់ខ្ពស់" ឬជនម្នាក់ក្នុងចំណោមជនទាំងឡាយដែល "ទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មកម្ពុជាប្រជាធិបតេយ្យនោះ[49] មើលរំលងយុត្តិសាស្ត្រដ៏ច្បាស់លាស់របស់ អ.ជ.ត.ក[50] ដែលត្រូវបានទទួលស្គាល់ជាដដែលៗដោយ អ.ជ.ស.ដ[51] ថា បញ្ហានេះមិនមានលក្ខណៈជាបញ្ហាយុត្តាធិការនោះទេ[52]។ ផ្ទុយទៅវិញ វាគឺជា "សេចក្តីសម្រេចផ្នែកគោលការណ៍ណែនាំ*តែមួយគត់*" ស្ថិតនៅក្នុងឆន្ទានុសិទ្ធិតែមួយគត់របស់សហព្រះរាជអាជ្ញា និង ស.ច.ស[53] ហើយ អ.ជ.ត.ក "មិនមានយុត្តាធិការក្នុងការចាប់ផ្តើមធ្វើការវាយតម្លៃណាមួយ" អំពីវាទេ[54]។ បញ្ហាយុត្តាធិការពិតប្រាកដតែមួយគត់ដែល អ.ជ.ត.ក ត្រូវតែបញ្ជាក់នោះគឺថា អោ អាន គឺជាមន្ត្រីខ្មែរក្រហម[55]។

18. ដូច្នេះ អោ អាន មិនមានលើកអំពីបញ្ហាប្រធានបទនៃការជំនុំជម្រះទេ។ គាត់មិនដែលជំទាស់ទេថា គាត់គឺជាមន្ត្រីខ្មែរក្រហម និងបានបញ្ជាក់វាជាថ្មីម្តងទៀតនៅក្នុងអញ្ញត្រកម្មទាំងអស់នេះ[56]។ ហើយគាត់ក៏មិនបានចោទអំពី "ការប្រើឆន្ទានុសិទ្ធិនេះត្រូវបានធ្វើឡើងដោយពុំសុទ្ធចិត្ត ឬការវិនិច្ឆ័យមិនត្រឹមត្រូវប្រកបដោយវិជ្ជាជីវៈ" លើផ្នែករបស់ ស.ច.ស ដើម្បីចាប់ផ្តើមអំណាចពិនិត្យឡើងវិញដែលនៅសេសសល់ "តិចតួចបំផុត" របស់ អ.ជ.ស.ដ នោះទេ[57]។

---

[48] ឯកសារ **D360** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៦៩៧-៧១២។#

[49] អញ្ញត្រកម្ម កថាខណ្ឌ ២២-២៨។#

[50] សំណុំរឿង០០១-ឯកសារ **F28** សាលដីកា *ឌុច* កថាខណ្ឌ ២៩។#

[51] សំណុំរឿង០០២-ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ជើងទំព័រ ៣៧។ សំណុំរឿង០០២-ឯកសារ **E313** សំណុំរឿង០០២/០១ សាលក្រម ជើងទំព័រ ៣១។#

[52] សំណុំរឿង០០១-ឯកសារ **F28** សាលដីកា *ឌុច* កថាខណ្ឌ ៦២-៨១។#

[53] សំណុំរឿង០០១-ឯកសារ **F28** សាលដីកា *ឌុច* កថាខណ្ឌ ៦៣, ៧៤-៧៥, ៧៧-៧៩, ៨០-៨១ (សម្រង់ត្រង់កថាខណ្ឌ ៨០ គូសបញ្ជាក់បន្ថែម)។#

[54] សំណុំរឿង០០១-ឯកសារ **F28** សាលដីកា *ឌុច* កថាខណ្ឌ ៨១។#

[55] សំណុំរឿង០០១-ឯកសារ **F28** សាលដីកា *ឌុច* កថាខណ្ឌ ៦១។#

[56] អញ្ញត្រកម្ម កថាខណ្ឌ ២៥-២៦។#

[57] សំណុំរឿង០០១-ឯកសារ **F28** សាលដីកា *ឌុច* កថាខណ្ឌ ៨០។#

## គ. ស.ព.អ មិនជំទាស់ទៅនឹងអញ្ញត្រកម្មរបស់ អោ អាន ទាក់ទងនឹងឧក្រិដ្ឋកម្មថ្នាក់ជាតិទេ

19. សហព្រះរាជអាជ្ញាបានរក្សារគោលជំហរយ៉ាងស៊ីចង្វាក់[58] ដែលត្រូវបានតម្កល់ដោយ អ.ប.ជ[59] ថា អនុលោមតាមមាត្រា ៣ថ្មី នៃច្បាប់ អ.វ.ត.ក នេះ អ.វ.ត.ក អាចអនុវត្តយុត្តាធិការលើឧក្រិដ្ឋកម្មនានាដែលមានចែងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ រួមបញ្ចូលទាំងអំពើមនុស្សឃាតគិតទុកជាមុន[60] និងមិនត្រូវបានរារាំងមិនឲ្យធ្វើដូច្នោះដោយអាជ្ញាយុកាល ១០ ឆ្នាំ ដែលមាននៅក្នុងមាត្រា ១០៩ នៃក្រមនោះទេ[61]។ ការណ៍នេះព្រោះថា អាជ្ញាយុកាលនេះត្រូវបានព្យួររហូតដល់យ៉ាងហោចណាស់ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ដែលបណ្តាលមកពីលក្ខខណ្ឌក្នុងប្រទេសកម្ពុជា ដែលបានរារាំងដល់ការស៊ើបអង្កេត ឬការចោទប្រកាន់ដ៏មានប្រសិទ្ធិភាពណាមួយចំពោះ អោ អាន។ លក្ខខណ្ឌទាំងនេះ ដែលបណ្តាលមកពីខ្មែរក្រហម រួមមាន កង្វះខាតប្រព័ន្ធយុត្តិធម៌ដែលដំណើរការក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ និងរបបសាធារណៈរដ្ឋប្រជាមានិតកម្ពុជា ចន្លោះឆ្នាំ ១៩៧៩ និង ១៩៨២។ បន្ទាប់មក រហូតទាល់តែព្រះរាជាណាចក្រកម្ពុជាត្រូវបានបង្កើតឡើងតាមរយៈការប្រកាស់ឲ្យប្រើរដ្ឋធម្មនុញ្ញរបស់ខ្លួន នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ សមត្ថភាពស៊ើបអង្កេត និងចោទប្រកាន់ក្នុងស្រុកត្រូវបានប៉ះពាល់យ៉ាងខ្លាំង[62]។ ហេតុដូច្នេះ ការពន្យាររយៈពេល

---

[58] ស.ព.អ សូមឲ្យ អ.ជ.ស.ដ មើលសារណាពីមុនរបស់សហព្រះរាជអាជ្ញា៖ សំណុំរឿង០០២-ឯកសារ **E51/5/3/1** កថាខណ្ឌ ១២-១៧ និង សំណុំរឿង០០២-ឯកសារ **E51/7/1**។#

[59] សំណុំរឿង០០២-ឯកសារ **D427/1/30** សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសំណោះស្រាយ កថាខណ្ឌ ២៧១-២៩២, ២៩៧។ *សូមមើលផងដែរ* ឯកសារ **D359/24 & D360/33**#ការពិចារណា កថាខណ្ឌ ៥៩៩-៦០៣ (ចៅក្រមអន្តរជាតិ)។#

[60] ក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦ មាត្រា ៥០១, ៥០៦។#

[61]#ក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦ មាត្រា ១០៩ នៅក្នុងផ្នែកពាក់ព័ន្ធចែងថា "អ្នកណាប្រព្រឹត្តឧក្រិដ្ឋកម្មកន្លងលើសពីដប់ឆ្នាំ [...] អ្នកនោះបានរួចផុតពីមានទោសហើយ" *សូមមើលផងដែរ* ក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦ មាត្រា ១១១ (ដោយបានបញ្ជាក់ថា រយៈពេលនៃអាជ្ញាយុកាលនេះត្រូវកំណត់ថ្ងៃ ពីត្រឹមថ្ងៃដែលបទល្មើសនោះបានប្រព្រឹត្តមក) និង មាត្រា ១១២-១១៤ (បានចែងថា កិច្ចស៊ើបសួរ និងការចោទប្រកាន់ ផ្តាច់ចិរវេលានៃអាជ្ញាយុកាល ដែលចិរវេលានេះចាប់ផ្តើមរាប់សាជាថ្មីចំនួន ១០ឆ្នាំវិញ ក្រោយកិច្ចនៃការផ្តាច់ចុងក្រោយ (នៅក្នុងករណីបទឧក្រិដ្ឋ)។ (ការបកប្រែក្រៅផ្លូវការត្រូវបានប្រើប្រាស់ពីមុនដោយ អ.ជ.ស.ដ។ *សូមមើល* សំណុំរឿង០០២-**E187**#សេចក្តីសម្រេចរបស់ អ.ជ.ស.ដ ស្តីពីអាជ្ញាយុកាល កំណត់សម្គាល់ជើងទំព័រលេខ ១៣)។ #

[62] សំណុំរឿង០០២-ឯកសារ **D427/1/30** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ២៨៥-២៨៦ *ដោយបានលើកឡើង ក្នុងចំណោមនោះ* សំណុំរឿង០០១-ឯកសារ **E187** សេចក្តីសម្រេចរបស់ អ.ជ.ស.ដ ស្តីពីអាជ្ញាយុកាល កថាខណ្ឌ ១៤, ១៦-១៧, ២៧, ២៩ (បានបញ្ជាក់ថា គេមិនរាប់អាជ្ញាយុកាលទេ កាលណាស្ថាប័នយុត្តិធម៌មិនដំណើរការ) កថាខណ្ឌ ១៩-២០, ២៥ (ការសន្និដ្ឋានរបស់ចៅក្រម អ.ជ.ស.ដ កម្ពុជាបីរូប ពាក់ព័ន្ធនឹង

អាជ្ញាយុកាលដោយរដ្ឋសភាជាតិរបស់ប្រទេសកម្ពុជាក្នុងឆ្នាំ២០០១ រយៈពេល២០ឆ្នាំ[63] និង ក្រោយមកក្នុងឆ្នាំ២០០៤ រយៈពេល ៣០ឆ្នាំ[64] មិនបានរំលោភលើគោលការណ៍នីត្យានុកូលភាព នោះទេ[65]។ ជាងនេះទៀត សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានសមភាពចំពោះមុខច្បាប់ មិនត្រូវបានរំលោភបំពានដោយការចោទប្រកាន់ដោយឧក្រិដ្ឋកម្មថ្នាក់ជាតិនៅ អ.វ.ត.ក ទេ[66] ហើយការកំណត់របស់ក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជាដែលថា មាត្រា៣ និងមាត្រា ៣ថ្មី នៃច្បាប់ អ.វ.ត.ក មិនបានរំលោភសិទ្ធិជាធម្មនុញ្ញណាមួយនោះ គឺស្ថាពរ ជាប់កាតព្វកិច្ច និងមិនអាច ត្រូវបានពិនិត្យឡើងវិញដោយតុលាការនេះទេ[67]។

20. ទោះជាយ៉ាងណា ស.ព.អ មិនស្វែងរកឲ្យមានដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ អោ អាន ចំពោះ ឧក្រិដ្ឋកម្មថ្នាក់ជាតិទេ[68] និងមិនជំទាស់ទៅនឹងការដកបទចោទប្រកាន់ទី៣ ចេញពីដីកាបញ្ជូនរឿង ទៅជំនុំជម្រះឡើយ។ ស.ព.អ ជឿជាក់ថា អំពើឧក្រិដ្ឋរបស់ អោ អាន ត្រូវបានរៀបរាប់ល្អជាង នៅពេលដែលត្រូវបានចាត់ប្រភេទយ៉ាងត្រឹមត្រូវតាមច្បាប់ថាជា ឧក្រិដ្ឋកម្មអន្តរជាតិនៃអំពើ ប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ជាងនេះទៀត ការកំណត់ប្រភេទអំពើនេះ ថាជាឧក្រិដ្ឋកម្មអន្តរជាតិតែមួយនោះ អាចជៀសវាងមិនឲ្យមានការប្តឹងផ្តល់មិនចាំបាច់ ក្នុង ទស្សនៈមួយដើម្បីធានាឲ្យមានកិច្ចដំណើរការនីតិវិធីឆាប់រហ័ស។ ស.ព.អ កត់សម្គាល់ថា នៅ ពេលដែលបញ្ហាដូចគ្នាបានមកដល់ចំពោះមុខ អ.ជ.ស.ដ ក្នុងសំណុំរឿង ០០១ ចៅក្រមបរាជ័យ មិនបានទទួលសំឡេងគាំទ្រសម្រាប់សេចក្តីសម្រេចមួយបាន[69]។

---

ការពុំមានសមត្ថកិច្ចតុលាការនៅក្នុងប្រទេសកម្ពុជា យ៉ាងហោចណាស់រហូតដល់ ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣)។ *សូមមើល ផងដែរ* ឯកសារ **D359/24** & **D360/33** សេចក្តីពិចារណា កថាខណ្ឌ ៥៥៩-៦០១, ៦០៣ (ចៅក្រមអន្តរជាតិ)។#

[63] ច្បាប់ អ.វ.ត.ក មាត្រា ៣។#

[64] ច្បាប់ អ.វ.ត.ក មាត្រា ៣ថ្មី។#

[65] សំណុំរឿង០០២-ឯកសារ **D427/1/30** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ២៨៧។ ឯកសារ **D359/24** & **D360/33** សេចក្តីពិចារណា កថាខណ្ឌ ៦០២។#

[66] សំណុំរឿង០០២-ឯកសារ **D427/1/30** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ២៨៨-២៩២។#

[67] សំណុំរឿង០០២-ឯកសារ **D427/1/30** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ២៧៩-២៨០។#

[68] ឯកសារ **D351/5** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង កថាខណ្ឌ ៦៣៦-៦៣៨។#

[69] សំណុំរឿង០០១-ឯកសារ **E187** សេចក្តីសម្រេចរបស់ អ.ជ.ស.ដ ស្តីពីអាជ្ញាយុកាល ដែលនៅក្នុងនោះ ចៅក្រមភាគច្រើន បីរូបគឺ ចៅក្រម និល ណុន ចៅក្រម ធូ មុនី និងចៅក្រម យ៉ា សុខន បានរកឃើញថា អាជ្ញាយុកាលត្រូវបានពន្យារហូតទាល់តែ

## ឃ. អ.វ.ត.ក មានយុត្តាធិការលើសហឧក្រិដ្ឋកម្មរួម (“JCE”)

21. អោ អាន មានកំហុសក្នុងការអះអាងរបស់គាត់[70]ថា អ.ជ.ស.ដ មិនមានយុត្តាធិការកាត់សេចក្តីអំពើរបស់ អោ អាន ដែលបានចោទប្រកាន់នៅក្រោមទម្រង់ JCE ដែលមានតម្លៃស្មើទៅនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មតាមមាត្រា ២៩ថ្មី នៃច្បាប់ អ.វ.ត.ក[71]។ អ.ជ.ត.ក[72] អ.ជ.ស.ដ[73] និង អ.ប.ជ[74] បានសម្រេចយ៉ាងស៊ីចង្វាក់គ្នាថា ទម្រង់ JCE I បានមានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ (“CIL”) ត្រឹមឆ្នាំ១៩៧៥ និងអាចប្រមើលឃើញ និងដឹងថាមានចែងនៅក្នុងច្បាប់។ ចំណុចនេះត្រូវបានបញ្ជាក់ដោយអង្គជំនុំជម្រះនៃតុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងទៀត ដែលបានពិនិត្យលើបញ្ហានេះ[75] គួរឲ្យកត់សម្គាល់បំផុតនោះគឺអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY ក្នុងរឿងក្តី *Tadić*[76] ក៏ដូចជារឿងក្តីក្រោយសង្គ្រាមលោកលើកទី II (រួមទាំង តែមិនកំណត់ត្រឹម[77] រឿងក្តីទាំងឡាយដែលត្រូវបានវិភាគនៅក្នុងរឿងក្តី *Tadić* នោះទេ) ធម្មនុញ្ញនូរីមប៊ើក និង

---

យ៉ាងហោចណាស់នៅឆ្នាំ១៩៩៣ រីឯចៅក្រម Silvia Cartwright និងចៅក្រម Jean-Marc Lavergne បានសន្និដ្ឋានថា រយៈពេលកំណត់បានផុតនៅឆ្នាំ១៩៨៩ ហើយថាហេតុដូច្នេះ ការពន្យារពេលនៅឆ្នាំ២០០១ គឺមិនអាចទៅរួចឡើយ។#

[70] អញ្ញត្រកម្ម កថាខណ្ឌ ៣០។ ឯកសារ **D360/5/1** បណ្តឹងឧទ្ធរណ៍របស់ អោ អាន កថាខណ្ឌ ១៧១-១៧៤។#

[71] សំណុំរឿង០០១-ឯកសារ **E188** សាលក្រម *ឌុច* កថាខណ្ឌ ៥១១។ សំណុំរឿង០០២-ឯកសារ **E100/6** សេចក្តីសម្រេចរបស់ អ.ជ.ស.ដ ស្តីពីសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ២២។ សំណុំរឿង០០២-ឯកសារ **E313** សាលក្រមសំណុំរឿង០០២/០១ កថាខណ្ឌ ៦៩០។ សំណុំរឿង ០០២-ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧០៦។#សំណុំរឿង០០២-ឯកសារ **D97/15/9** សាលដីការបស់ អ.ប.ជ ស្តីពីសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៤៩។#

[72] សំណុំរឿង០០២-ឯកសារ **F36** សាលដីកាសំណុំរឿង០០២/០១ កថាខណ្ឌ ៧៧៥-៧៨៩, ៨០៧-៨១០, ១០៩៣។#

[73] សំណុំរឿង០០១-ឯកសារ **E188** សាលក្រម *ឌុច* កថាខណ្ឌ ៥១២។ សំណុំរឿង០០២-ឯកសារ **E100/6** សេចក្តីសម្រេចរបស់ អ.ជ.ស.ដ ស្តីពីសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ២២។ សំណុំរឿង០០២-ឯកសារ **E313** សាលក្រម សំណុំរឿង០០២/០១ កថាខណ្ឌ ៦៩១។ សំណុំរឿង០០២-ឯកសារ **E465** សាលក្រមសំណុំរឿង០០២/០២ កថាខណ្ឌ ៣៧០៧។#

[74] សំណុំរឿង០០២-ឯកសារ **D97/15/9** សាលដីការបស់ អ.ប.ជ ស្តីពីសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៥៧-៦៩, ៧២។ #

[75] *សូមមើល ឧទា.* *Tadić* សាលដីកា កថាខណ្ឌ ១៨៥-២២៩។ *Tolimir* សាលដីកា កថាខណ្ឌ ២៨១-២៨៣។ *Karemera* សេចក្តីសម្រេចស្តីពីសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ១២-១៦។ *Brima* សាលដីកា កថាខណ្ឌ ៧២-៨០។ *Ayyash* សេចក្តីសម្រេចស្តីពីច្បាប់ជាធរមាន កថាខណ្ឌ ២៣៧-២៣៨។#

[76] *Tadić* សាលដីកា កថាខណ្ឌ ១៩៥-២២០។#

[77] *សូមមើលផងដែរ ឧទា.* *Justice Case* TWC Vol. III ទំព័រទី ៩៥៦, ៩៨៥, ១០៦៣, ១០៨១, ១០៩៣-១០៩៥, ១១២៣, ១១២៨, ១១៥៥-១១៥៦, ១១៧៥-១១៧៧។ រឿងក្តី *RuSHA*, TWC Vol. V,#ទំព័រ១០៣, ១០៦។ *Klein និងគូកន* ទំព័រទី ៤៦-៥៤២។ *Buck និងគូកន* ទំព័រទី ៣៩-៤១។ *Golkel*#*និងគូកន* ទំព័រទី ៤៥-៤៧។ *Rohde និងគូកន* ទំព័រទី ៥៤-៥៥។#

តូក្យូ[78] ច្បាប់ក្រុមប្រឹក្សាគ្រប់គ្រងលេខ ១០ ("CCL 10")[79] និងការបញ្ជាក់ជាឯកច្ឆ័ន្ទរបស់ធម្មនុញ្ញនូរ៉ឹមប៊ើក និងសាលក្រមរបស់មហាសន្និបាត អ.ស.ប ក្នុងឆ្នាំ១៩៤៦[80]។

22. ចំពោះការប្រកាសរបស់សាលក្រមអំពី JCE អ.ជ.ស.ដ បានសម្រេចថា ខ្លួនជាប់កាតព្វកិច្ចដោយខ្លឹមសារ និងវិសាលភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងមិនមានអំណាចធ្វើការកែប្រែវិការៈដែលបានចោទឡើយ[81]។ ក្នុងករណីណាក៏ដោយ អោ អាន មិនបង្ហាញអំពីការរំលោភបំពានណាមួយនៃគោលការណ៍នីត្យានុកូលភាព ក្នុងការប្រកាសរបស់ ស.ច.ស.អ អំពីធាតុផ្សំសត្យានុម័តិនៃ JCE នោះទេ[82]។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះបានសម្រេចយ៉ាងត្រឹមត្រូវ[83]ថា វាមានលក្ខណៈគ្រប់គ្រាន់ក្នុងការកំណត់អត្តសញ្ញាណអ្នកចូលរួមក្នុង JCE ជាប្រភេទ ឬជាក្រុមមនុស្ស[84] និងបានកំណត់និយមន័យក្រុម JCE យ៉ាងច្បាស់លាស់ក្នុងការដាក់បញ្ចូល កែ ពក, អោ អាន និងកម្មាភិបាល ប.ក.ក ផ្សេងទៀត[85]។ ចំពោះវិសាលភាពភូមិសាស្ត្រនៃ JCE វិញ[86] អោ អាន ខកខានមិនបានបង្ហាញឲ្យច្បាស់ថាតើវាមានកំហុសដោយរបៀបណា ក្នុងការសន្និដ្ឋានថា ជនជាប់ចោទបានចូល

[78] #បក្ខន្តិកៈនូរ៉ឹមប៊ើក #មាត្រា ៦។ #បក្ខន្តិកៈតូក្យូ មាត្រា ៥ (អនុវត្តបានចំពោះឧក្រិដ្ឋកម្មទាំងអស់)។ #

[79] ច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យ លេខ១០ មាត្រា II (២)។#

[80] សេចក្តីបញ្ជាក់ពីគោលការណ៍ច្បាប់អន្តរជាតិ ដែលបានទទួលស្គាល់ដោយធម្មនុញ្ញនៃតុលាការនូរ៉ឹមប៊ើក G.A. Res. 95(I), ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៤៦។#

[81] សំណុំរឿង០០២-ឯកសារ **E74** ចម្លើយតបរបស់ អ.ជ.ស.ដ ទៅនឹងសំណើសុំចំនួនដប់ ទំព័រទី ២។#

[82] អញ្ញត្រកម្ម កថាខណ្ឌ ៣០។#

[83] *ផ្ទុយពី* អញ្ញត្រកម្ម កថាខណ្ឌ ៣០។ ឯកសារ **D360/5/1** បណ្តឹងឧទ្ធរណ៍របស់ អោ អាន កថាខណ្ឌ ១៧៥។#

[84] ឯកសារ **D360** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១១៥។ *សូមមើលបន្ថែមទៀត* សំណុំរឿង០០១-ឯកសារ **E188** សាលក្រម *ឌុច* កថាខណ្ឌ ៥០៨។#សំណុំរឿង០០២-ឯកសារ **E313** សាលក្រមសំណុំរឿង០០២/០១ កថាខណ្ឌ ៦៩២។ សំណុំរឿង០០២-ឯកសារ **E465** សាលក្រមសំណុំរឿង០០២/០២ កថាខណ្ឌ ៣៧០៨។ *Brđanin* សាលដីកា កថាខណ្ឌ ៤៣០។ *Prlić* សាលដីកា កថាខណ្ឌ ១៥២២។ *Nizeyimana* សាលដីកា កថាខណ្ឌ ៣១៨។ រឿងក្តី *Justice Case* TWC Vol III #ទំព័រ ១១៥៥-១១៥៦ ("តុលាការរបស់ចុងចោទ [...] គឺគ្រាន់តែជាឧបករណ៍នៅក្នុងកម្មវិធីរបស់*មេដឹកនាំរដ្ឋណាហ្ស៊ី*នៃការចោទប្រកាន់ និងការត្រួតពិនិត្យតែប៉ុណ្ណោះ។ ចំនួនដែលចុងចោទអាចលុបបំបាត់នៅក្នុងសមត្ថភាពរបស់គាត់មានសភាពតូចជាងចំនួនដែលចូលរួមនៅក្នុងការធ្វើទុក្ខបុកម្នេញ និងការសម្លាប់រង្គាលទ្រង់ទ្រាយធំ ដោយ*មេដឹកនាំ*ដែលគាត់បម្រើការឲ្យ មិនបន្ធូបន្ថយការចូលរួមចំណែករបស់គាត់ក្នុង*កម្មវិធីរបស់មេដឹកនាំទាំងអស់នោះទេ*។ ") (គូសបញ្ជាក់បន្ថែម))។ *Einsatzgruppen* #TWC Vol IV #ទំព័រទី ១៥-១៦។#

[85] ឯកសារ **D360** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៩៥, ៨២៤។#

[86] អញ្ញត្រកម្ម កថាខណ្ឌ ៣០។ ឯកសារ **D360/5/1** បណ្តឹងឧទ្ធរណ៍របស់ អោ អាន កថាខណ្ឌ ១៧៦។#

រួមក្នុងការអនុវត្តផែនការឧក្រិដ្ឋរួម ដែលលាតសន្ធឹងលើដែនដីភូមិសាស្ត្រដ៏ធំទូលាយជាងដែនដីភូមិសាស្ត្រចង្អៀត ដែលឧក្រិដ្ឋកម្មដែលជនជាប់ចោទត្រូវបានចោទប្រកាន់នោះបានកើតឡើង។ ក្នុងករណីណាក៏ដោយ អោ អាន ត្រូវបានចោទប្រកាន់អំពីឧក្រិដ្ឋកម្មនៅទូទាំងភូមិភាគកណ្តាលទាំងមូល - ជាពិសេស អំពើប្រល័យពូជសាសន៍ចាម[87]។ ជាចុងក្រោយ ការអះអាងរបស់ អោ អាន ទាក់ទងនឹងការភ្ជាប់បញ្ចូលគ្នាដែលបានចោទប្រកាន់អំពីគោលបំណងរួមនៃក្រុម JCE ផ្សេងៗគ្នានេះ[88] លើកឡើងអំពីបញ្ហាចម្រុះអំពីអង្គហេតុ និងអង្គច្បាប់ដែលត្រូវដោះស្រាយនៅចុងបញ្ចប់នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ[89]។

## ង. អ.វ.ត.ក មានយុត្តាធិការលើការរៀបចំផែនការ

23. ផ្ទុយទៅនឹងការអះអាងរបស់ អោ អាន[90] អ.វ.ត.ក មានយុត្តាធិការកាត់សេចក្តីអំពើរបស់ អោ អាន ដែលត្រូវបានចោទប្រកាន់ក្រោមការរៀបចំផែនការ ទម្រង់នៃការទទួលខុសត្រូវដែលមានរៀបរាប់នៅក្នុងមាត្រា ២៩ថ្មី នៃច្បាប់ អ.វ.ត.ក។ អ.ជ.ស.ដ បានសម្រេចយ៉ាងស៊ីជម្រៅថា ការរៀបចំផែនការមានអត្ថិភាពជាទម្រង់នៃការទទួលខុសត្រូវក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រឹមឆ្នាំ ១៩៧៥ និងដឹងថាជាបទល្មើស និងដឹងថាមានច្បាប់ចែង[91]។ ចំណុចនេះត្រូវបានបញ្ជាក់ដោយធម្មនុញ្ញនូរ៉ឹមប៊ើក និងតូក្យូ[92] សាលក្រមតុលាការ IMT[93] ច្បាប់ក្រុមប្រឹក្សាគ្រប់គ្រងលេខ ១០[94] និងរឿងក្តី *វេជ្ជសាស្ត្រ*[95]។ ការរៀបចំផែនការក៏ត្រូវបានកំណត់ថាជាបទឧក្រិដ្ឋដោយមាត្រា

---

[87] ឯកសារ **D360** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ បទល្មើស១ KH 01588971 ផ្អែកលើកថាខណ្ឌ ៥៩០-៦៧៧។ *សូមមើលបន្ថែមទៀត* ឯកសារ **D359/24** & **D360/33** សេចក្តីពិចារណា កថាខណ្ឌ ៦៣២។#

[88] អញ្ញត្រកម្ម កថាខណ្ឌ ៣០។ ឯកសារ **D360/5/1** បណ្តឹងឧទ្ធរណ៍របស់ អោ អាន កថាខណ្ឌ ១៧៧។#

[89] សំណុំរឿង០០២-ឯកសារ **E306**#ត៍មានស្តីពីអញ្ញត្រកម្ម កថាខណ្ឌ ២។#

[90]#អញ្ញត្រកម្ម កថាខណ្ឌ ៣១។ ឯកសារ **D360/5/1** បណ្តឹងឧទ្ធរណ៍របស់ អោ អាន កថាខណ្ឌ ១៧៨-១៧៩។ #

[91] សំណុំរឿង០០១-ឯកសារ **E188** សាលក្រម *ឌុច* កថាខណ្ឌ ៤៧៣-៤៧៥, ៤៧៨។ សំណុំរឿង០០២-ឯកសារ **E313** សាលក្រមសំណុំរឿង០០២/០១ កថាខណ្ឌ ៦៩៧។ សំណុំរឿង០០២-ឯកសារ **E465** សាលក្រមសំណុំរឿង០០២/០២ កថាខណ្ឌ ៣៧០៤។ *សូមមើលផងដែរ* សំណុំរឿង០០១-ឯកសារ **F28** សាលដីកា *ឌុច* កថាខណ្ឌ ១៣៨។#

[92] លក្ខន្តិកៈនូរ៉ឹមប៊ើក#មាត្រា ៦។#លក្ខន្តិកៈតូក្យូ មាត្រា ៥ (អាចអនុវត្តបានចំពោះគ្រប់ឧក្រិដ្ឋកម្ម)។#

[93] សំណុំរឿង០០១-ឯកសារ **F28** សាលដីកា *ឌុច* កថាខណ្ឌ ១៣៨ *ដោយបានលើកឡើងពី*#សាលក្រមតុលាការ IMT ទំព័រទី ២៧៩-៣៤១។ *សូមមើលជាពិសេស* ទំព័រ ២៩២, ២៩៧-២៩៨, ៣០០។#

[94] ច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យ លេខ១០ មាត្រា II ១(ក), II (២)(ឃ)។#

[95]#*សំណុំរឿងវេជ្ជសាស្ត្រ* TWC Vol II ទំព័រ ១៩៨ (Karl Brandt) ទំព័រ ២៤០ (Rudolf Brandt) ទំព័រ ២៧១ (Gerhard Rose)។ #

២២៣, ២៣៩ និង ២៩០ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ផងដែរ[96]។ អវត្តមាននៃការរៀបចំផែនការនៅក្នុងលិខិតុបករណ៍អន្តរជាតិមួយចំនួន ដូចជា អនុសញ្ញាប្រល័យពូជសាសន៍ ឬ លក្ខន្តិកៈទីក្រុងរ៉ូម មិនប៉ះពាល់ដល់ភាពច្បាស់ក្រឡែតរបស់វាជាទម្រង់នៃការទទួលខុសត្រូវនោះទេ។

## ច. អ.វ.ត.ក មានយុត្តាធិការលើការទទួលខុសត្រូវរបស់ថ្នាក់លើ ដូចដែលបានកំណត់និយមន័យក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ

24. អោ អាន បកស្រាយច្បាប់ខុសក្នុងការអះអាងថា ការទទួលខុសត្រូវរបស់ថ្នាក់លើដែលអាចអនុវត្តបានចំពោះមេបញ្ជាការស៊ីវិលនៅក្រៅជម្លោះប្រដាប់អាវុធអន្តរជាតិ (“IAC”) មិនបង្កើតបានជាផ្នែកមួយនៃច្បាប់ទម្លាប់អន្តរជាតិ នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យឡើយ[97]។ អ.ជ.ស.ដ[98] និង អ.ប.ជ[99] បានសម្រេចយ៉ាងស៊ីចង្វាក់គ្នាថា ការទទួលខុសត្រូវរបស់ថ្នាក់លើ ដែលអាចអនុវត្តបានទាំងថ្នាក់លើជាយោធា និង ជាស៊ីវិល ត្រូវបានទទួលស្គាល់ក្នុងច្បាប់ទម្លាប់អន្តរជាតិ ត្រឹមឆ្នាំ ១៩៧៥ និងអាចប្រមើលដឹងថាជាបទល្មើស និងដឹងថាមានច្បាប់ចែង។ ក្នុងចំណោមរឿងក្តីក្រោយឆ្នាំ ១៩៧៥ ដែលត្រូវបានវិភាគដោយអង្គជំនុំជម្រះទាំងអស់នេះ រឿងក្តីមួយចំនួនធំទាក់ទងនឹងថ្នាក់លើជាជនស៊ីវិល[100]។ ខណៈដែលពួកវាពាក់ព័ន្ធទៅនឹងរយៈកាលនៃជម្លោះប្រដាប់អាវុធអន្តរជាតិ កាទទួលខុសត្រូវរបស់ថ្នាក់លើផ្តោតលើការទទួលខុសត្រូវរបស់បុគ្គល មិនមែនលើ

[96] *សូមមើល* សំណុំរឿង០០១-ឯកសារ **E188** សាលក្រម *ឌុច* កថាខណ្ឌ ៤៧៤។ សំណុំរឿង០០២-ឯកសារ **E465** សាលក្រម សំណុំរឿង០០២/០២ កំណត់សម្គាល់ជើងទំព័រទី ១២៣៣៨។ ឯកសារ **D359/24 & D360/33** សេក្តីពិចារណា កថាខណ្ឌ ៥៨៧ (ចៅក្រមអន្តរជាតិ)។#

[97] អញ្ញត្រកម្ម កថាខណ្ឌ ៣២។ ឯកសារ **D360/5/1** បណ្តឹងឧទ្ធរណ៍របស់ អោ អាន កថាខណ្ឌ ១៨០-១៨១។#

[98] សំណុំរឿង០០១-ឯកសារ **E188** សាលក្រម *ឌុច* កថាខណ្ឌ ៤៧៦-៤៧៨។ សំណុំរឿង០០២-ឯកសារ **E313** សាលក្រម សំណុំរឿង០០២/០១ កថាខណ្ឌ ៧១៤, ៧១៨-៧១៩។ សំណុំរឿង០០២-ឯកសារ **E465** សាលក្រម សំណុំរឿង០០២/០២ កថាខណ្ឌ ៣៧០៤, ៣៧២៥។#

[99] សំណុំរឿង០០២-ឯកសារ **D427/1/30** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៤១៣-៤៦០។ សំណុំរឿង០០២-ឯកសារ **D427/2/15**#សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១៩០-២៣២។ *សូមមើលផងដែរ* ឯកសារ **D359/24 & D360/33** សេចក្តីពិចារណា កថាខណ្ឌ ៥៩២-៥៩៣ (ចៅក្រមអន្តរជាតិ)។#

[100] *សូមមើល ឧទា.* របាយការណ៍ឆ្នាំ១៩១៩ របស់គណៈកម្មាធិការទទួលបន្ទុកចំពោះអ្នកបង្កសង្គ្រាម និងការដាក់ទណ្ឌកម្ម កថាខណ្ឌ ១២១។ *សំណុំរឿង Pohl*#WC Vol V, ទំព័រទី ១០៥១-១០៥៦។ *សំណុំរឿងវេជ្ជសាស្ត្រ* TWC Vol. II ទំព័រទី ២០៦។ *សំណុំរឿង តាមក្រសួងនានា* TWC Vol XII,#ទំព័រទី ១៧-១៨, Vol. XIV ទំព័រ ៥៤៥-៥៤៦ (Gottlob Berger)។ *សំណុំរឿង Roechling* TWC Vol XIV,#ទំព័រទី ១១៣៥-១១៣៦, ១១៤០។#

បរិបទនៃជម្លោះប្រដាប់អាវុធអន្តរជាតិទេ[101] ហើយ អោ អាន ខកខានមិនបានបង្ហាញថា ការប្រើប្រាស់ការទទួលខុសត្រូវរបស់ថ្នាក់លើនេះផ្អែកលើអត្ថិភាពនៃជម្លោះបែបនោះ។ តាមពិត អង្គជំនុំជម្រះនេះបានអនុវត្តទម្រង់នៃការទទួលខុសត្រូវនេះចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើប្រល័យពូជសាសន៍ ដោយមិនតម្រូវឱ្យមានចំណងទាក់ទងទៅនឹងជម្លោះប្រដាប់អាវុធអន្តរជាតិឡើយ[102]។

25. អោ អាន ខកខានមិនបានបង្ហាញ[103]អំពីមូលហេតុដ៏គួរឱ្យជឿជាក់ណាមួយ ដើម្បីងាកចេញពីយុត្តិសាស្ត្រដែលបានបង្កើតឡើងរបស់អង្គជំនុំជម្រះនេះថា (i) "ទំនាក់ទំនងរវាងហេតុនិងផល"[104] មិនមែនជាធាតុផ្សំសត្យានុម័តនៃការទទួលខុសត្រូវរបស់ថ្នាក់លើក្នុងច្បាប់ទម្លាប់អន្តរជាតិឡើយ[105] និង (ii) *ធាតុផ្សំអត្តនោម័តិ*ដែលអាចអនុវត្តបានគឺថា ថ្នាក់លើ "ត្រូវតែបានដឹង ឬមានហេតុផលដឹង" ថាឧក្រិដ្ឋកម្មមួយហៀបនឹងកើតមានឡើង ឬត្រូវបានប្រព្រឹត្តឡើងដោយថ្នាក់ក្រោមបង្គាប់របស់ខ្លួន[106]។ ទោះបីជាការវិភាគដ៏ហ្មត់ចត់នៃច្បាប់ក្រោយសង្គ្រាមលោកលើកទី II ដោយអង្គជំនុំ

---

[101] ឯកសារ **D359/24 & D360/33** សេក្តីពិចារណា កថាខណ្ឌ ៥៩៤ (ចៅក្រមអន្តរជាតិ) និងការលើកឡើងនៅក្នុងនោះ។ *Hadžihasanović និង Kubura* សេចក្តីសម្រេចស្តីពីការទទួលខុសត្រូវរបស់ថ្នាក់លើ កថាខណ្ឌ ២០។#

[102] *សូមមើល ឧទា.* សំណុំរឿង០០២-ឯកសារ **E313** សាលក្រមសំណុំរឿង០០២/០១ កថាខណ្ឌ ១៧៧, ៨៩៨, ៩១៧, ៩៣៩។ សំណុំរឿង០០២-ឯកសារ **E465** សាលក្រមសំណុំរឿង០០២/០២ កថាខណ្ឌ ៣០១, ៤១៧៩, ៤១៨៧-៤១៩៧, ៤២០០, ៤៣៣៥។ *សូមមើល ផងដែរ* *Hadžihasanović* សេចក្តីសម្រេចស្តីពីយុត្តាធិការ កថាខណ្ឌ ៧៥ (ពិភាក្សាពីអត្ថិភាពនៃការទទួលខុសត្រូវរបស់ ថ្នាក់លើ៖ "អំពើសកម្មនៅក្រោមក្រមដែលបានព្រាងនេះ" រួមមាន អំពើប្រល័យពូជសាសន៍ ដែលអាចត្រូវបានប្រព្រឹត្តក្នុងពេល អវត្តមានជម្លោះប្រដាប់អាវុធ [...]")។#

[103] អញ្ញត្រកម្ម កថាខណ្ឌ ៣២។ ឯកសារ **D360/5/1** បណ្តឹងឧទ្ធរណ៍របស់ អោ អាន កថាខណ្ឌ ១៨១។#

[104] វាចាំបាច់ត្រូវបង្ហាញពីចំណងទាក់ទងហេតុនិងផលរវាងការខកខានរបស់ថ្នាក់លើក្នុងការការពារ ឬ ដាក់ទណ្ឌកម្មលើឧក្រិដ្ឋកម្មរបស់អ្នកនៅក្រោមបង្គាប់ និងការកើតឡើងនៃឧក្រិដ្ឋកម្មទាំងនេះ។#

[105] សំណុំរឿង០០១-ឯកសារ **E188** សាលក្រម *ឌុច* កថាខណ្ឌ ៥៣៨-៥៤៧។ សំណុំរឿង០០២-ឯកសារ **E313** សាលក្រមសំណុំរឿង០០២/០១ កថាខណ្ឌ ៧១៥-៧២១។ សំណុំរឿង០០២-ឯកសារ **E465** សាលក្រមសំណុំរឿង០០២/០២ កថាខណ្ឌ ៣៧២៥-៣៧២៦។ អ.ស.ព កត់សម្គាល់ថាលក្ខខណ្ឌតម្រូវនៃទំនាក់ទំនងរវាងហេតុនិងផល នឹងមិនសមស្របទៅនឹងកាតព្វកិច្ចដាក់ទណ្ឌកម្ម ដែលបានកើតឡើង*នៅក្រោយ* ការប្រព្រឹត្តឧក្រិដ្ឋកម្មទេ។#

[106] សំណុំរឿង០០១-ឯកសារ **E188** សាលក្រម *ឌុច* កថាខណ្ឌ ៥៤៣។ សំណុំរឿង០០២-ឯកសារ **E313** សាលក្រមសំណុំរឿង០០២/០១ កថាខណ្ឌ ៧១៥។ សំណុំរឿង០០២-ឯកសារ **E465** សាលក្រមសំណុំរឿង០០២/០២ កថាខណ្ឌ ៣៧២៥។#

ជម្រះ អ.វ.ត.ក[107] ក៏មិនមានត្រង់ណា អោ អាន បានយោងសំអាងឯកសារយោងមុនឆ្នាំ១៩៧៥ ណាមួយ ដើម្បីគាំទ្រការអះអាងរបស់គាត់ឡើយ។ លក្ខខន្តិកៈទីក្រុងរ៉ូម[108] មិនបានឆ្លុះបញ្ចាំងយ៉ាងស៊ីចង្វាក់នូវច្បាប់ទំនៀមទម្លាប់អន្តរជាតិទេ[109] ជាពិសេសក្នុងរយៈពេលចន្លោះឆ្នាំ ១៩៧៥-១៩៧៩។

### ឆ. អ.វ.ត.ក មានយុត្តាធិការលើអំពើអមនុស្សធម៌ផ្សេងៗទៀត ដែលបានកំណត់និយមន័យក្នុង ដីកាបញ្ជូនរឿងទៅជំនុំជម្រះ

26. អ.ជ.ត.ក[110] អ.ប.ជ[111] និង អ.ជ.ស.ដ[112] ទាំងអស់គ្នាបានបញ្ជាក់ថា ត្រឹមឆ្នាំ១៩៧៥ អំពើអមនុស្សធម៌ផ្សេងៗទៀត (“OIA”) ត្រូវបានកំណត់ថាជាបទឧក្រិដ្ឋក្នុងច្បាប់ទម្លាប់អន្តរជាតិជាផ្នែកដែលនៅសេសសល់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយអាចប្រមើលឃើញ និងដឹងថាមានចែងនៅក្នុងច្បាប់។ ការរកឃើញនេះត្រូវបានគាំទ្រដោយច្បាប់ និងយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទី II[113]។ ផ្ទុយទៅនឹងការអះអាងរបស់ អោ អាន[114] មិនមានលក្ខខណ្ឌតម្រូវ

---

[107] *សូមមើល ឧទា.* សុំណុំរឿង០០២-ឯកសារ **D427/1/30** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៤១៣-៤៦០។ ឯកសារ **D359/24** & **D360/33** សេចក្តីពិចារណា កថាខណ្ឌ ៥៩២-៥៩៤ (ចៅក្រមអន្តរជាតិ) និងការយោងសំអាងខាងក្នុងនោះ។#

[108] លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា ២៨(ខ)(i) (តម្រូវថា “ថ្នាក់លើ បានដឹងឮ ឬមិនយកចិត្តទុកដាក់ដោយចេតនាចំពោះព័ត៌មានដែលត្រូវបានបញ្ជាក់យ៉ាងច្បាស់ [...]”)។#

[109] លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា ២១។ *Katanga និង Ngudjolo Chui* #សេចក្តីសម្រេចស្តីពីការបញ្ជាក់ កថាខណ្ឌ ៥០៦-៥០៨។ *Šainović* សាលដីកា កថាខណ្ឌ ១៦៤៨។ **D359/24** & **D360/33** សេចក្តីពិចារណា កថាខណ្ឌ ៥៨៨ (ចៅក្រម អន្តរជាតិ)។#

[110] សំណុំរឿង០០២-ឯកសារ **F36** សាលដីកាសំណុំរឿង០០២/០១ កថាខណ្ឌ ៥៦៧, ៥៧៦-៥៨៦។#

[111] សំណុំរឿង០០២-ឯកសារ **D427/1/30** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣៧១, ៣៨៥-៣៨៨, ៣៩៥-៣៩៦, ៣៩៨។ សំណុំរឿង០០២-ឯកសារ **D427/2/15**#សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១៣០-១៣១, ១៥៦, ១៦៥។ ឯកសារ **D257/1/8** សេចក្តីពិចារណាលើការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ៖ ចៅក្រមអន្តរជាតិ កថាខណ្ឌ ៩ (ត្រង់ទំព័រ ២៦-២៧)។#

[112] សំណុំរឿង០០១-ឯកសារ **E188** សាលក្រម *ឌុច* កថាខណ្ឌ ៣៦៧។ សំណុំរឿង០០២-ឯកសារ **E313** សាលក្រមសំណុំរឿង០០២/០១ កថាខណ្ឌ ៤៣៥។ សំណុំរឿង០០២-ឯកសារ **E465** សាលក្រមសំណុំរឿង០០២/០២ កថាខណ្ឌ ៧២៣។#

[113] *សូមមើល ឧទា.* Eichmann កថាខណ្ឌ ២០៤។ *សំណុំរឿងតាមក្រសួងនានា* TWC Vol XIV, ទំពីរ ៣៣៩, ៩៩១-៩៩២។ *សំណុំរឿងវេជ្ជសាស្ត្រ* TWC Vol II, ទំព័រទី ១៧៤-១៨០, ១៩៨។ លក្ខន្តិកៈនូរឹមប៊ើក#មាត្រា ៦(គ)។#លក្ខន្តិកៈតូក្យូ មាត្រា ៥(គ)។ CCL 10#មាត្រា II(១)(គ)។ គោលការណ៍នូរឹមប៊ើក ឆ្នាំ១៩៥០ គោលការណ៍ VI(គ)។#

[114] អញ្ញត្រកម្ម កថាខណ្ឌ ៣៣។ ឯកសារ **D360/5/1** បណ្តឹងឧទ្ធរណ៍របស់ អោ អាន កថាខណ្ឌ ១៨៧-១៨៩។#

ដែលថាអំពើដែលជាមូលដ្ឋាននៃអំពើអមនុស្សធម៌ផ្សេងទៀតត្រូវបានកំណត់ជាបទល្មើសក្នុងច្បាប់អន្តរជាតិនៅពេលនៃការប្រព្រឹត្តនោះទេ ហើយធ្វើដូច្នេះនឹងធ្វើឲ្យប្រភេទនេះគ្មានអត្ថន័យ[115]។ អំពើសកម្ម ឬអំពើអកម្ម គ្រាន់តែមានសភាព និងទម្ងន់ស្រដៀងគ្នាគ្រប់គ្រាន់ទៅនឹងអំពើអមនុស្សធម៌ផ្សេងៗទៀតដែលបានរាយឈ្មោះ[116]។ អោ អាន មិនបានផ្តល់ការគាំទ្រណាមួយសម្រាប់លក្ខខណ្ឌតម្រូវនៃភាពឧក្រិដ្ឋជាមូលដ្ឋាន និងសំអាងអំណះអំណាងរបស់គាត់លើយុត្តិសាស្ត្រតុលាការ ICTY ដែល (i) ត្រូវបានបដិសេធ[117] (ii) ឬ គាំទ្រយុត្តិសាស្ត្រ អ.វ.ត.ក ឡើយ[118]។ ជាផលវិបាក

---

[115] សំណុំរឿង០០២-ឯកសារ **F36** សាលដីកាសំណុំរឿង០០២/០១ កថាខណ្ឌ ៥៨៥។ សំណុំរឿង០០២-ឯកសារ **E313** សាលក្រមសំណុំរឿង០០២/០១ កថាខណ្ឌ ៤៣៦។ សំណុំរឿង០០២-ឯកសារ **E465** សាលក្រមសំណុំរឿង០០២/០២ កថាខណ្ឌ ៧២៥-៧២៦។ សំណុំរឿង០០២-ឯកសារ **D427/1/30** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣៧១, ៣៧៨។ សំណុំរឿង០០២-ឯកសារ **D427/2/15**#សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១៥៦។#

[116] សំណុំរឿង០០២-ឯកសារ **F36** សាលដីកាសំណុំរឿង០០២/០២ កថាខណ្ឌ ៥៨៤-៥៨៦។ សំណុំរឿង០០១-ឯកសារ **E188** សាលក្រម *ឌុច* កថាខណ្ឌ ៣៦៧។ សំណុំរឿង០០២-ឯកសារ **E313** សាលក្រមសំណុំរឿង០០២/០១ កថាខណ្ឌ ៤៣៨, ៤៤០។ សំណុំរឿង០០២-ឯកសារ **E465** សាលក្រមសំណុំរឿង០០២/០២ កថាខណ្ឌ ៧២៥-៧២៦។ សំណុំរឿង០០២-ឯកសារ **D427/1/30** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣៩៥-៣៩៦។ សំណុំរឿង០០២-ឯកសារ **D427/2/15**#សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១៦០-១៦២។ ឯកសារ **D257/1/8** សេចក្តីពិចារណាលើការរៀបអាពាហ៍ ពិពាហ៍ដោយបង្ខំ៖ ថៅក្រមអន្តរជាតិ កថាខណ្ឌ ១០, ១៥ (ត្រង់ទំព័រ ២៧-៣០)។ *Krajišnik* សាលដីកា កថាខណ្ឌ ៣៣១។ *Brima* សាលដីកា កថាខណ្ឌ ១៩៨។#

[117] **D360/5/1** បណ្តឹងឧទ្ធរណ៍របស់ អោ អាន កំណត់សម្គាល់ជើងទំព័រទី ៤៧៦, ៤៧៨, ៤៨៩ *ដោយបានយោងពី* *Stakić* សាលក្រម កថាខណ្ឌ ៧១៩, ៧២១ (*ត្រូវបានបដិសេធដោយឥស្សរៈចិត្ត* ដោយ សាលដីកា *Stakić* កថាខណ្ឌ ៣១៣-៣១៧)។#

[118] ឯកសារ **D360/5/1** បណ្តឹងឧទ្ធរណ៍របស់ អោ អាន កំណត់សម្គាល់ជើងទំព័រទី ៤៧៦, ៤៧៨ *ដោយបានលើកឡើងពី* *Kordić & Čerkez* សាលដីកា កថាខណ្ឌ ១១៧ (*សូមមើលផងដែរ* កថាខណ្ឌ ៤៧២, ៥៤៥-៥៤៦, ៥៧៣, ៩៩៦, ១០០២, ១០០៦ បានរកឃើញថាមិនមានការរំលោភបំពានលើគោលការណ៍*ពុំមានបទល្មើសបើគ្មានច្បាប់ចែង* (*nullum crimen*) ក្នុងករណីដែលធាតុផ្សំសម្រាប់អំពើអមនុស្សធម៌ផ្សេងៗទៀតមិនត្រូវបានបំពេញ រួមទាំងការរំលោភសេពសន្ថវៈ ក្នុងរូបភាពជា "ការវាយប្រហារយ៉ាងធ្ងន់ធ្ងរទៅលើសេចក្តីថ្លៃថ្នូររបស់មនុស្ស") និង សាលដីកា *Kupreškić* កថាខណ្ឌ ៥៦៣, ៦១៨ (*សូមមើលផងដែរ* កថាខណ្ឌ ៥៦៦, ៦២៣, ៨១៨-៨២២, ៨៣០-៨៣២ ដោយផ្អែកលើបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិដើម្បីកាត់ទោសជនជាប់ចោទនៃអំពើអមនុស្សធម៌ផ្សេងៗទៀត)។#

នៃកង្វះខាតលក្ខខណ្ឌតម្រូវឧក្រិដ្ឋភាពនេះ អ.ជ.ត.ក បានបញ្ជាក់ច្បាស់[119]ថា មិនចាំបាច់បញ្ជាក់អំពី "ធាតុផ្សំសត្យានុម័តិ" សម្រាប់អំពើជាមូលដ្ឋាននេះទេ[120]។

27. ជាចុងក្រោយ អោ អាន មិនបានកំណត់អត្តសញ្ញាណ[121]កំហុសណាមួយនៅក្នុងបទដ្ឋាន*ធាតុផ្សំអត្តនោម័តិ* ដែលអនុវត្តដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះ[122] ដែលមិនខុសគ្នាជាសត្យានុម័តិពីការប្រកាសពីមុនរបស់ អ.ជ.ស.ដ ទេ[123] និងខ្ពស់ជាងបទដ្ឋានដែលត្រូវបានបញ្ជាក់ដោយ អ.ជ.ត.ក និងត្រូវបានអនុវត្តដោយ អ.ជ.ស.ដ នៅក្នុងរឿងក្តី០០២/០២[124]។ គាត់គ្រាន់តែដកស្រង់ចេញពីធាតុផ្សំនៃឧក្រិដ្ឋកម្មរបស់តុលាការ ICC ឆ្នាំ២០០២ តែប៉ុណ្ណោះ - ដែល ដូចដែលបានកត់សម្គាល់ មិនឆ្លុះបញ្ចាំងជាចាំបាច់អំពីច្បាប់ទំនៀមទម្លាប់អន្តរជាតិ[125]ឡើយ - ដោយមិនបានចង្អុលបង្ហាញ

---

[119] សំណុំរឿង០០២-ឯកសារ **F36** សាលដីកាសំណុំរឿង០០២/០១ កថាខណ្ឌ ៥៨៩។#

[120] អញ្ញត្រកម្ម កថាខណ្ឌ ៣៣។ ឯកសារ **D360/5/1** បណ្តឹងឧទ្ធរណ៍របស់ អោ អាន កថាខណ្ឌ ១៨៩។#

[121] អញ្ញត្រកម្ម កថាខណ្ឌ ៣៣។ ឯកសារ **D360/5/1** បណ្តឹងឧទ្ធរណ៍របស់ អោ អាន កថាខណ្ឌ ១៩០-១៩១។#

[122] ឯកសារ **D360** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៨០ ("ចារីត្រូវតែបានប្រព្រឹត្តអំពើសកម្ម ឬអកម្ម ដោយមានចេតនាបង្កការឈឺចាប់យ៉ាងធ្ងន់ធ្ងរមកលើរូបរាងកាយ ឬផ្លូវចិត្ត ឬប្រព្រឹត្តអំពើហិង្សាយ៉ាងធ្ងន់ធ្ងរមកលើជនរងគ្រោះ ដែលធ្វើឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ នៅពេលដែលបានប្រព្រឹត្តអំពើសកម្ម ឬអកម្មនោះ ឬបានដឹងថា អំពើសកម្ម ឬអកម្មនោះទំនងជាបង្កការឈឺចាប់យ៉ាងធ្ងន់ធ្ងរ មកលើរូបរាងកាយ ឬផ្លូវចិត្ត ឬប្រព្រឹត្តអំពើហិង្សាយ៉ាងធ្ងន់ធ្ងរមកលើសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ")។#

[123] សំណុំរឿង០០១-ឯកសារ **E188** សាលក្រម *ឌុច* កថាខណ្ឌ ៣៧១។ សំណុំរឿង០០២-ឯកសារ **E313** សាលក្រមសំណុំរឿង០០២/០១ កថាខណ្ឌ ៤៣៧។#

[124] សំណុំរឿង០០២-ឯកសារ **F36** សាលដីកាសំណុំរឿង០០២/០១ កថាខណ្ឌ ៥៨០។ សំណុំរឿង០០២-ឯកសារ **E465** សាលក្រមសំណុំរឿង០០២/០២ កថាខណ្ឌ ៧២៤ (គ្រាន់តែតម្រូវថា "អំពើសកម្ម ឬអកម្ម ត្រូវបានប្រព្រឹត្តដោយចេតនា" ប៉ុណ្ណោះ)។ នេះគឺជាកំហុសនៅក្នុងការរៀបរាប់របស់ដីកាបញ្ជូនរឿងទៅជំនុំជម្រះស្តីពី*ធាតុផ្សំអត្តនោម័ត* សម្រាប់អំពើអមនុស្សធម៌ផ្សេងៗទៀត (*សូមមើលយោងខាងលើ* ជើងទំព័រទី ១២២)។ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើអមនុស្សធម៌ផ្សេងៗទៀត គឺជាប្រភេទដែលនៅសេសសល់ ហើយវានឹងមិនត្រឹមត្រូវទេក្នុងការដាក់បញ្ចូលនូវ*ធាតុផ្សំអត្តនោម័ត* ដែលមិនបានរកឃើញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងៗទៀត (*ឧទា.* ការនិរទេស និង ការធ្វើឲ្យទៅជាទាសករ មិនតម្រូវឲ្យភ័ស្តុតាងបញ្ជាក់ថា ចារីបានមានចេតនា ឬបានដឹងពីព្យសនកម្មដែលអាចកើតមាន ដែលការនិរទេស និង ការធ្វើឲ្យទៅជាទាសករ កើតមានចំពោះជនរងគ្រោះ)។ លក្ខខណ្ឌតម្រូវបែបដូច្នេះ នឹងបណ្តាលឲ្យមានលទ្ធផលមិនសមហេតុផល ដោយសារតែវានឹងចាត់ទុកថាចារីមានចេតនាប្រព្រឹត្តអំពើដដែលនោះខុសគ្នា អាស្រ័យលើទស្សនៈអត្តនោម័តរបស់ពួកគេផ្ទាល់ចំពោះព្យសនកម្មដែលអំពើសកម្មនោះទំនងជាបានបង្កឡើង។#

[125] *សូមមើលយោងខាងលើ* កថាខណ្ឌ ២៥។#

ទៅកាន់ភ័ស្តុតាងណាមួយដែលបង្ហាញថា*ធាតុផ្សំអត្តនោម័តិ* នៅខាងក្នុងនោះផ្ទុះបញ្ហាំងច្បាប់ទំនៀមទម្លាប់អន្តរជាតិចន្លោះឆ្នាំ១៩៧៥ និង ១៩៧៩[126]។

## ជ. អ.វ.ត.ក មានយុត្តាធិការលើការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងរូបភាពជាអំពើអមនុស្សធម៌ផ្សេងៗទៀត

28. ការអះអាងរបស់ អោ អាន[127] ថា អ.ជ.ស.ជ មិនមានយុត្តាធិការលើការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងរូបភាពជាអំពើអមនុស្សធម៌ផ្សេងៗទៀត គឺគ្មានមូលដ្ឋានទេ។ ដូចបានបង្ហាញខាងលើ មិនមានលក្ខខណ្ឌតម្រូវណាត្រូវបង្ហាញឲ្យដាច់ដោយឡែកពីគ្នានូវ "ភាពឧក្រិដ្ឋជាមូលដ្ឋាន" ឬត្រូវបញ្ជាក់អំពី "ធាតុផ្សំ" នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំឡើយ[128]។ អំណះអំណាងរបស់ អោ អាន ចំពោះថាតើលក្ខណៈ និងទម្ងន់ស្រដៀងគ្នាទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀត - រួមបញ្ចូលទាំង (i) ទំនាក់ទំនងទៅវិញទៅមករវាងកាលៈទេសៈអង្គហេតុនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរួមដំណេកដោយបង្ខំ និង (ii) ការបែងចែកពីគ្នារវាងការអនុវត្តមុន និងក្រោយឆ្នាំ ១៩៧៥ - ទាំងអស់នេះពាក់ព័ន្ធទៅនឹងបញ្ហាចម្រុះគ្នានៃច្បាប់ និងអង្គហេតុដែលនឹងសក្តិសមសម្រាប់ការវាយតម្លៃតែនៅពេលចុងបញ្ចប់នៃការជំនុំជម្រះប៉ុណ្ណោះ[129]។

## ឈ. អ.វ.ត.ក មានយុត្តាធិការលើអំពើប្រល័យពូជសាសន៍ ដូចដែលបានកំណត់និយមន័យនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ

29. អ.វ.ត.ក មានយុត្តាធិការលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍[130]។ ខណៈដែលអះអាងថាដីកាបញ្ជូនរឿងទៅជំនុំជម្រះលប់ចោលលក្ខខណ្ឌតម្រូវនៃធាតុផ្សំបរិបទ[131] ជាថ្មីម្តងទៀតមានតែការយោង

---

[126] ឯកសារ **D360/5/1** បណ្តឹងឧទ្ធរណ៍របស់ អោ អាន កថាខណ្ឌ ១៩០។#

[127] អញ្ញត្រកម្ម កថាខណ្ឌ ៣៤។ ឯកសារ **D360/5/1** បណ្តឹងឧទ្ធរណ៍របស់ អោ អាន កថាខណ្ឌ ១៩២-១៩៣។#

[128] *សូមមើលយោងខាងលើ* កថាខណ្ឌ ២៦។#

[129] ឯកសារ **D359/24 & D360/33** សេចក្តីពិចារណា កថាខណ្ឌ ១៦០ (ជាឯកច្ឆ័ន្ទ)។ ឯកសារ **D257/1/8** សេចក្តីពិចារណាលើការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ៖ ចៅក្រមអន្តរជាតិ កថាខណ្ឌ ១៨ (ត្រង់ទំព័រ ៣១)។ សំណុំរឿង០០២-ឯកសារ **D427/1/30** សាលដីកាលើ បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣៩៧។ សំណុំរឿង០០២-ឯកសារ **E306#**តំមានស្តីពីអញ្ញត្រកម្ម កថាខណ្ឌ ២។#

[130] *សូមមើល ឧទា.* ច្បាប់ អ.វ.ត.ក មាត្រា ៤។ សំណុំរឿង០០២-ឯកសារ **E465** សាលក្រមសំណុំរឿង០០២/០២ កថាខណ្ឌ ៧៨៤-៧៨៩។#

[131] អញ្ញត្រកម្ម កថាខណ្ឌ ៣៥។ ឯកសារ **D360/5/1** បណ្តឹងឧទ្ធរណ៍របស់ អោ អាន កថាខណ្ឌ ១៩៦។#

ទៅលើធាតុផ្សំនៃឧក្រិដ្ឋកម្មរបស់តុលាការ ICC ឆ្នាំ២០០២[132] តែប៉ុណ្ណោះ អោ អាន ខកខានមិនបានបង្ហាញថា លក្ខខណ្ឌតម្រូវបែបនេះកើតមាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ត្រឹមឆ្នាំ ១៩៧៥ ជាពិសេសដោយសារតែវា (i) មិនមាននៅក្នុងអនុសញ្ញាប្រល័យពូជសាសន៍ (ii) ត្រូវបានបដិសេធដោយអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY ថា "មិនត្រូវបានកំណត់ ដោយ [ច្បាប់ទំនៀមទម្លាប់អន្តរជាតិ]" ក្នុងអំឡុងពេលទសវត្សឆ្នាំ ១៩៩០[133] និង (iii) មិនត្រូវបាន អនុវត្តដោយ អ.ជ.ស.ដ ទោះបីជាការវិភាគដ៏ហ្មត់ចត់របស់វាអំពីច្បាប់ដោយសារតែវាមាន សុពលភាពក្នុងឆ្នាំ ១៩៧៥[134]។

30. ដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនមានកំហុសអង្គច្បាប់ទេ នៅក្នុងនិយមន័យរបស់ខ្លួនអំពីក្រុមដែល ត្រូវការពារ (ជនជាតិចាម) ឬចំពោះ *ធាតុផ្សំអត្តនោម័តិ*[135]។ វាបានទទួលស្គាល់យ៉ាងច្បាស់ថា ក្រុមនេះត្រូវតែកំណត់អត្តសញ្ញាណជាវិជ្ជមាន[136] និងត្រូវបានផ្តោតគោលដៅសម្រាប់ការបំផ្លិច បំផ្លាញ "ដោយមានចេតនាបែបនោះ"[137]។ ជាងនេះទៀត វាបានបង្ហាញថា អោ អាន និងសមាជិក JCE ផ្សេងទៀតបានផ្តោតគោលដៅលើជនជាតិចាម តាមវិធីនានាដែលពាក់ព័ន្ធជាពិសេសទៅនឹង អត្តសញ្ញាណរបស់ពួកគេ ថាជាជាតិពន្ធុ និងក្រុមសាសនាខុសគេ ដោយមានចេតនាបំផ្លិចបំផ្លាញ ក្រុមនោះ "ដោយមានចេតនាបែបនោះ"[138]#គឺដូចគ្នាទៅនឹង អ.ជ.ស.ដ បានធ្វើនៅក្នុងសំណុំរឿង ០០២/០២[139]។

## ញ. សិទ្ធិជំនុំជម្រះដោយត្រឹមត្រូវរបស់ អោ អាន ត្រូវបានការពារនៅទូទាំងកិច្ចដំណើរការនីតិវិធីទាំងមូល

31. អោ អាន ផ្តល់មូលដ្ឋានការជំទាស់របស់គាត់លើវិធាន ៨៩(១)(ខ) ដោយចោទប្រកាន់អំពីការ រំលោភបំពានលើសិទ្ធិជំនុំជម្រះដោយត្រឹមត្រូវ ក្នុងអំឡុងពេលស៊ើបអង្កេត ថាធ្ងន់ធ្ងរ និងមិនអាច

---

[132] *សូមមើលយោងខាងលើ* កថាខណ្ឌ២៥។#

[133] *Krstić* សាលដីកា កថាខណ្ឌ ២២៣-២២៤។#

[134] សំណុំរឿង០០២-ឯកសារ **E465** សាលក្រមសំណុំរឿង០០២/០២ កថាខណ្ឌ ៧៨៤-៨០៤។#

[135] *ផ្ទុយពី* អញ្ញត្រកម្ម កថាខណ្ឌ ៣៥។ ឯកសារ **D360/5/1** បណ្តឹងឧទ្ធរណ៍របស់ អោ អាន កថាខណ្ឌ ១៩៧-១៩៨។#

[136] ឯកសារ **D360** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៨៨-៨៩។#

[137] ឯកសារ **D360** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៨៥, ៨៨, ៩៤, ៩៨។#

[138] #ឯកសារ **D360** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៩៥, ២១៨, ២២០, ៣០២-៣០៣, ៣០៥, ៣១១, ៣១៣, ៨១៨។ #

[139] *សូមមើល ឧទា.* សំណុំរឿង០០២-**E465** សាលក្រមសំណុំរឿង០០២/០២ កថាខណ្ឌ ៣២២៨, ៣៣៤៥, ៣៩៩៣។#

ជួសជុលបាន ដែលផលប៉ះពាល់គ្រួតគ្នារបស់វាធ្វើឱ្យការជំនុំជម្រះត្រឹមត្រូវមិនអាចធ្វើទៅបាន[140]។ ទោះជាយ៉ាងណា យុត្តិសាស្ត្រពីមុនរបស់ អ.ជ.ស.ដ បញ្ជាក់ច្បាស់ថា អញ្ញត្រកម្មដែលចោទអំពីវិការៈក្នុងការស៊ើបអង្កេត ជាទូទៅមិនអាចទទួលយកបានទេនៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនេះ តាមវិធាន ៨៩(១)(ខ) នៃវិធានផ្ទៃក្នុង ឬក្នុងកម្រិតណាក៏ដោយ។ ក្នុងករណីដែលអាចធ្វើទៅបាន[141] ការជំទាស់បែបណាមួយត្រូវតែលើកឡើងនៅមុនពេលដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះចូលជាស្ថាពរ ហើយវិធានផ្ទៃក្នុងមិនប្រមើលទុកជាមុនអំពីការត្រួតពិនិត្យរបស់ អ.ជ.ស.ដ លើភាពត្រឹមត្រូវផ្នែកនីតិវិធីនៃកិច្ចស៊ើបសួរឡើយ ក្រោយពេលដែលបានទទួលរឿងក្តីហើយ[142]។ វិធាន៧៦(៧) នៃវិធានផ្ទៃក្នុងចែងថា មិនមានវិការៈផ្នែកនីតិវិធីអាចត្រូវបានលើកឡើងនៅចំពោះមុខ អ.ជ.ស.ដ ទេ ហើយក្នុងវិធាន ៨៩(១)(គ) អ.ជ.ស.ដ អាចគ្រាន់តែពិចារណាលើមោឃភាពនៃកិច្ចផ្នែនីតិវិធី ដែលបានធ្វើឡើង "ក្រោយពេលដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានដាក់" តែប៉ុណ្ណោះ។ ទោះជាយ៉ាងណា ដូចបានរៀបរាប់ខាងលើ[143] អ.ជ.ស.ដ មិនមានអំណាចរំលត់កិច្ចដំណើរការនីតិវិធីទេ លើកលែងតែផ្អែកលើមូលដ្ឋាននានាដែលត្រូវបានគ្រោងទុកដោយមាត្រា ៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលមិនរួមបញ្ចូលវិការៈដែលបានចោទប្រកាន់នៅក្នុងកិច្ចស៊ើបសួរឡើយ និងវិធាននីតិវិធីដែលបានបង្កើតឡើងនៅកម្រិតអន្តរជាតិបង្ហាញអំពីចំណុចចាប់ផ្តើមអប្បបរមាខ្ពស់បំផុតសម្រាប់អនុញ្ញាតឱ្យមានការរំលត់ (ឬផ្អាក) កិច្ចដំណើរការនីតិវិធី។

32. ក្នុងរឿងក្តីនេះ អោ អាន មានឱកាសជាច្រើនដើម្បីកត់សម្គាល់វិការៈដែលបានចោទប្រកាន់មុនពេលដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះចូលជាស្ថាពរ។ តាមពិតនោះ ការតវ៉ារបស់ អោ អាន ទាក់ទងនឹង៖ (i) ការចូលមើលសំណុំរឿង សមភាពនៃការតតាំងក្តី និងសិទ្ធិទទួលបានការជូនដំណឹងអំពីការចោទប្រកាន់ក្នុងអំឡុងពេលស៊ើបអង្កេត[144] (ii) សិទ្ធិក្នុងណែនាំមេធាវីតាមការ

[140] អញ្ញត្រកម្ម កថាខណ្ឌ ៣៦-៤០។ **D360/5/1** បណ្តឹងឧទ្ធរណ៍របស់ អោ អាន កថាខណ្ឌ ២០៧-២១៨, ២២៣-២៣០។ #

[141] អ.ជ.ស.ដ បានអនុញ្ញាតឱ្យមានការពិនិត្យឡើងវិញជាពិសេស កាលណា (១) ជនជាប់ចោទមិនមានឱកាសរកឃើញវិការៈខាងនីតិវិធីនៅមុនពេលបើកការជំនុំជម្រះ ឬ (២) វាចំនងជាចាំបាច់ដើម្បីធានាពីភាពត្រឹមត្រូវនៃការជំនុំជម្រះ។ *សូមមើល ឧទា.* សំណុំរឿង០០២-ឯកសារ **E306/5** សេចក្តីសម្រេចរបស់ អ.ជ.ស.ដ ស្តីពីការនិរទេស កថាខណ្ឌ ៥-៦។#

[142] វិធាន ៧៦(៧)។ សំណុំរឿង០០២-**E116** សេចក្តីសម្រេចលើសំណើរបស់ នួន ជា ពាក់ព័ន្ធនឹងភាព ត្រឹមត្រូវនៃកិច្ចស៊ើបសួរ កថាខណ្ឌ ១៥, ១៧។ សំណុំរឿង០០២-**E74** ចម្លើយតបរបស់ អ.ជ.ស.ដ ទៅនឹងសំណើសុំ ចំនួនដប់ ទំព័រទី ២។#

[143] *សូមមើលយោងខាងលើ* កថាខណ្ឌ១៥។#

[144] អញ្ញត្រកម្ម កថាខណ្ឌ ៣៧។ ឯកសារ **D360/5/1** បណ្តឹងឧទ្ធរណ៍របស់ អោ អាន កថាខណ្ឌ ២១៥-២១៧, ២២៤, ២២៩។#

ជ្រើសរើសរបស់ខ្លួនផ្ទាល់[145] (iii) ការអនុវត្តការស៊ើបអង្កេតដោយធ្វេសប្រហែលដែលបានស្នានឡើង[146] និង (iv) វិធានមតិភាគច្រើនលើសលុប “ដែលប្រឆាំងនឹងសច្ចធានីរទោស” ដែលបានស្នើឡើង និងផលវិបាកនៃគោលជំហរស្វ័យប្រវត្តិដែលថា “ការស៊ើបអង្កេតត្រូវបន្តទៅមុខ”[147] ទាំងអស់នេះត្រូវបានប្តឹងផ្តល់ដោយរូបគាត់នៅចំពោះមុខ អ.ប.ជ ហើយជាចុងក្រោយត្រូវបានបដិសេធចោល[148]។ ជាងនេះទៀត អោ អាន បំភ្លៃសំអាងហេតុសម្រាប់ការបដិសេធរបស់ ស.ច.ស ចំពោះសំណើរបស់គាត់សុំឱ្យបំពេញកិច្ចស៊ើបសួរ។ ពួកវាមិនត្រូវបានច្រានចោលដោយមូលហេតុខ្វះថវិការ ឬសម្ពាធម្ចាស់ជំនួយ ឬដោយសារភ័ស្តុតាងដែលស្នើសុំនោះ “មិនត្រូវតាមទ្រឹស្តីសំណុំរឿងដែលបានបង្កើតរួចហើយ”[149] តែផ្ទុយទៅវិញ ដោយសារតែពួកវា*ជាអាទិ៍* មិនពាក់ព័ន្ធ[150] មានលក្ខណៈទាយស្មានច្រើន[151] មិនមានភាពច្បាស់លាស់គ្រប់គ្រាន់[152] ត្រួតគ្នាមិនចាំបាច់[153] មិនមាន

---

[145] អញ្ញត្រកម្ម កថាខណ្ឌ ៣៧។ ឯកសារ **D360/5/1** បណ្តឹងឧទ្ធរណ៍របស់ អោ អាន កថាខណ្ឌ ២១៤, ២២៥។#

[146] អញ្ញត្រកម្ម កថាខណ្ឌ ៣៨។ ឯកសារ **D360/5/1** បណ្តឹងឧទ្ធរណ៍របស់ អោ អាន កថាខណ្ឌ ៥៨, ៦៣, ៦៦, ៦៨, ៧២, ៧៦, ៧៩, ៩៥, ២១៧, ២២៥។#

[147] អញ្ញត្រកម្ម កថាខណ្ឌ ៣៨។ ឯកសារ **D360/5/1** បណ្តឹងឧទ្ធរណ៍របស់ អោ អាន កថាខណ្ឌ ២០៧, ២១០-២១២, ២២៥។#

[148] *សូមមើល ឧទា.* ***ការចូលមើលសំណុំរឿង៖*** ឯកសារ **D359/24** & **D360/33** សេចក្តីពិចារណា កថាខណ្ឌ ១៦៥។ ឯកសារ# **D121/4/1/4** ការពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ អោ អាន ស្តីពីការចូលពិនិត្យមើលឯកសារសំណុំរឿង។#***សិទ្ធិក្នុងការមានមេធាវី៖*** ឯកសារ **D359/24** & **D360/33** សេចក្តីពិចារណា កថាខណ្ឌ ១៦៦។ ***ការអនុវត្តធ្វេសប្រហែសរបស់អ្នកស៊ើបអង្កេតដែលបានចោទប្រកាន់៖*** # ឯកសារ **D338/1/5** សាលដីកាលើសំណើ សុំធ្វើមោឃភាពលើកំណត់ហេតុស្តាប់ចម្លើយនានាដែធ្វើឡើងដោយអ្នកស៊ើប អង្កេតបីរូប។ ឯកសារ **D296/1/1/4** សាលដីកាលើសំណើ សុំធ្វើមោឃភាពកំណត់ហេតុនៃការស្តាប់ចម្លើយដែលមិនមានខ្សែអាត់សំឡេង។ ឯកសារ **D359/24** & **D360/33** សេចក្តីពិចារណា កថាខណ្ឌ ១៦៤។ ***សំឡេងភាគច្រើនលើសលុប៖*** ឯកសារ **D359/24** & **D360/33** សេចក្តីពិចារណា កថាខណ្ឌ ១៦៣។#

[149] អញ្ញត្រកម្ម កថាខណ្ឌ ៣៨។ ឯកសារ **D360/5/1** បណ្តឹងឧទ្ធរណ៍របស់ អោ អាន កថាខណ្ឌ ២១៦, ២២៥។#

[150] *សូមមើល ឧទា.* ឯកសារ **D260/1**#កថាខណ្ឌ ១២-២៤។ ឯកសារ **D276/1**#កថាខណ្ឌ ៣៣។ ឯកសារ **D300/2**# កថាខណ្ឌ១៥។ ឯកសារ **D311/1**#កថាខណ្ឌ ៦៥។ ឯកសារ **D320/1**#កថាខណ្ឌ ១១-១៤។#

[151] *សូមមើល ឧទា.* ឯកសារ **D276/1**#កថាខណ្ឌ ២៣-២៤, ៤១, ៤៩។ ឯកសារ **D277/1**#កថាខណ្ឌ ២១, ២៤។ ឯកសារ **D244/1**#កថាខណ្ឌ ១៨-២១។#

[152] *សូមមើល ឧទា.* ឯកសារ **D276/1**#កថាខណ្ឌ ១៨, ៣០-៣២, ៣៤-៣៥, ៤៧, ៥២។ ឯកសារ **D277/1**#កថាខណ្ឌ ១៨, ២២-២៣។ ឯកសារ **D320/1**#កថាខណ្ឌ ១១-១៣, ១៥-១៧, ១៩-២០។ ឯកសារ **D189/2**#កថាខណ្ឌ២៦។#

[153] *សូមមើល ឧទា.* ឯកសារ **D244/1**#កថាខណ្ឌ ១៥, ២៦។ ឯកសារ **D276/1**#កថាខណ្ឌ ៣៨-៤០។ ឯកសារ **D188/1/1**# កថាខណ្ឌ១៦-២០, ២៥-២៦, ២៩-៣០, ៤២-៤៤។#

លទ្ធភាពទទួលបានដោយសារមិនមានកិច្ចសហការ/ការចូលរួមពីភាគីទីបី[154] ឬស្ទើតែមិនមានមូលដ្ឋានទាំងស្រុង[155]។ រាល់ពេលនីមួយៗ អោ អាន បានប្ដឹងឧទ្ធរណ៍ការបដិសេធទាំងអស់នេះទៅកាន់ អ.ប.ជ បណ្ដឹងឧទ្ធរណ៍ទាំងអស់នោះត្រូវបានច្រានចោល *ជាឯកច្ឆ័ន្ទ*[156] មិនដូច អោ អន បានលើកឡើង[157] ថា ដោយសារតែ "ការបដិសេធទាំងស្រុង" ដោយចៅក្រមជាតិនៃ អ.ប.ជ នោះឡើយ។

33. ការតវ៉ារបស់ អោ អាន អំពីភាពមិនច្បាស់លាស់ដែលបានចោទឡើងអំពីការចោទប្រកាន់នានាប្រឆាំងនឹងរូបគាត់ ដែលបណ្ដាលមកពីការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នារបស់ ស.ច.ស[158] ត្រូវបានដោះស្រាយយ៉ាងហ្មត់ចត់ដោយ អ.ប.ជ[159] ហើយការចោទប្រកាន់ទាំងនោះ ពេលនេះមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលបានប្ដឹងទៅកាន់ អ.ជ.ស.ដ គឺមានលក្ខណៈច្បាស់លាស់ខ្លាំងណាស់។ ជាចុងក្រោយ បើទោះជា អ.ប.ជ បានព្រមាន ស.ច.ស ចំពោះការពន្យារពេលចេញដីកាដំណោះស្រាយរបស់ពួកគេក៏ដោយ[160] ក៏ខ្លួនមិនបានរកឃើញថា អោ អាន ទទួលរងព្យសនកម្ម ឬថា ការពន្យារពេលនេះផ្ដល់យុត្តិកម្មការរំលត់កិច្ចដំណើរការនីតិវិធីនោះទេ។ អោ អាន មិនដែលត្រូវបានឃុំខ្លួននៅ អ.វ.ត.ក ទេ ហើយផលប៉ះពាល់ដែលថាឈ្មោះរបស់គាត់ត្រូវបានគេដឹងជាសាធារណៈថាជាបុគ្គលម្នាក់ស្ថិតក្រោមការស៊ើបអង្កេតនោះ មិនមែនជាផលប៉ះពាល់ធ្ងន់ធ្ងរដោយសារពេលវេលាដែលបានចំណាយដើម្បីបិទបញ្ចប់សំណុំរឿងនេះទេ។

---

[154] *សូមមើល ឧទា.* ឯកសារ **D326**#កថាខណ្ឌ ២៣-៤៥។ ឯកសារ **D277/1**#កថាខណ្ឌ ២១, ៣០-៣១, ៤៥-៤៦។#

[155] *សូមមើល ឧទា.* ឯកសារ **D345/1**#(ស.ច.ស.អ បានធ្វើការវិភាគយ៉ាងទូលំទូលាយលើភាពមិនស្របគ្នាដែលបានចោទប្រកាន់ រវាងខ្សែ អាត់សំឡេង និងកំណត់ហេតុស្ដាប់ចម្លើយនានា និងដោយមានការលើកលែងចំពោះភាពមិនស្របគ្នាពីរ និងកំហុសក្នុងការបកប្រែភាសាមួយ បានរកឃើញថា "ភាពមិនស៊ីសង្វាក់គ្នាទាំងអស់ផ្សេងទៀតដែលមេធាវីការពារក្ដីបានចោទគឺមិនមានមូលដ្ឋាន ឬក៏មិនជាក់ស្ដែង ឬក៏មិនប៉ះពាល់ដល់ អោ អាន ទេ។)")។ ឯកសារ **D189/2**#កថាខណ្ឌ២២។#

[156] ឯកសារ **D260/1/1/3** សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្ដីសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី៥។ ឯកសារ **D276/1/1/3** សាលដីការសម្រេចលើបណ្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចលើសំណើសុំបំពេញ កិច្ចស៊ើបសួរលើកទី៦។ ឯកសារ **D277/1/1/4** សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្ដីសម្រេចលើសំណើសុំបំពេញ កិច្ចស៊ើបសួរលើកទី៧។ ឯកសារ **D343/4** សាលដីកា សម្រេចលើបណ្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចលើ សំណើសុំបំពេញកិច្ចស៊ើបសួរលើកទី១០។ ឯកសារ **D320/1/1/4** សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្ដីសម្រេចលើ សំណើសុំបំពេញកិច្ចស៊ើបសួរលើកទី១២។#

[157] #អញ្ញត្រកម្ម កថាខណ្ឌ ៣៨។ ឯកសារ **D360/5/1** បណ្ដឹងឧទ្ធរណ៍របស់ អោ អាន កថាខណ្ឌ ២១៨, ២២៥។ #

[158] អញ្ញត្រកម្ម កថាខណ្ឌ ៣៨។ ឯកសារ **D360/5/1** បណ្ដឹងឧទ្ធរណ៍របស់ អោ អាន កថាខណ្ឌ ២១៥។#

[159] #ឯកសារ **D359/24 & D360/33** សេចក្ដីពិចារណា កថាខណ្ឌ ៨៨-១២៤, ១៦៥ (ជាឯកច្ឆ័ន្ទ)។ #

[160] ឯកសារ **D359/24 & D360/33** សេចក្ដីពិចារណា កថាខណ្ឌ ៦០-៧២ (ជាឯកច្ឆ័ន្ទ)។#

34. អ.ប.ជ មិនមែនជាស្ថាប័នឧទ្ធរណ៍ ឬស្ថាប័នពិនិត្យឡើងវិញទាក់ទងនឹងសេចក្ដីសម្រេចរបស់ អ.ប.ជ[161] នោះទេ ហើយ អោ អាន មិនបានកំណត់អត្តសញ្ញាណផលប៉ះពាល់ជាក់ស្ដែងអំពីកង្វះខាត ដែលបានចោទប្រកាន់ទាំងអស់នេះ នៅក្នុងការស៊ើបអង្កេតលើភាពត្រឹមត្រូវនៃការជំនុំជម្រះទេ ហើយគាត់ក៏មិនបានបង្ហាញថាការរំលត់រឿងក្ដីនេះគឺជាមធ្យោបាយតែមួយគត់ដែលមានដើម្បីដោះស្រាយការរំលោភបំពានដែលបានចោទប្រកាន់ឡើង[162]។ អ.ជ.ស.ដ និង អ.ជ.ត.ក ពេលនេះមានកាតព្វកិច្ចធានាសិទ្ធិជំនុំជម្រះដោយត្រឹមត្រូវរបស់ អោ អាន ហើយគាត់មិនបានផ្ដល់ហេតុផលណាមួយដើម្បីឱ្យជឿបានថា ពួកគេនឹងមិនបំពេញតួនាទីនេះឱ្យដល់កម្រិតបទដ្ឋានខ្ពស់បំផុតនោះទេ។

## V. សេចក្ដីសន្និដ្ឋាន

35. អាស្រ័យហេតុនេះ សម្រាប់មូលហេតុដូចបានរៀបរាប់ខាងលើ ស.ព.អ សូមសន្និដ្ឋានថា អញ្ញត្រកម្មរបស់ជនជាប់ចោទគួរត្រូវបានច្រានចោល[163]៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ | **លោកស្រី Brenda J. HOLLIS** សហព្រះរាជអាជ្ញាអន្តរជាតិ | ភ្នំពេញ | |

[161] សំណុំរឿង០០២-**E116** សេចក្ដីសម្រេចលើសំណើរបស់ នួន ជា ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ កថាខណ្ឌ ១៨។#

[162] សំណុំរឿង០០២-ឯកសារ **E116** សេចក្ដីសម្រេចលើសំណើរបស់ នួន ជា ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ កថាខណ្ឌ ១៨។ *ផ្ទុយពី* អញ្ញត្រកម្ម កថាខណ្ឌ ៣៦, ៣៩-៤០។#

[163] ស.ព.អ បញ្ជាក់ឡើងវិញថាខ្លួនមិនជំទាស់ទៅនឹងការដកបទចោទទី៣ (ឧក្រិដ្ឋកម្មថ្នាក់ជាតិ) ចេញពីដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះទេ។#